# ៧០ឆ្នាំ នៃវត្តមាន
# បម្រើអោយវិស័យវិទ្យាសាស្ត្រ និង សុខាភិបាល
# នៅកម្ពុជា




# PHNOM PENH

INSTITUT PASTEUR DU CAMBODGE 1953 - 2023



ផ្ទាំងគំនូរប្រេង ដោយ Albert Edelfelt នៅឆ្នាំ១៨៨៦ បង្ហាញអំពីលោក Louis Pasteur នៅក្នុងមន្ទីរពិសោធន៍របស់លោក នៅសាលា Ecole Normale Supérieure ឆ្នាំ១៨៨៥ កំពុងកាន់ដបមួយមានផ្ទុកខួរឆ្អឹងខ្នងរបស់សត្វទន្សាយ ដែលគេបានចាក់វីរុសឆ្កែឆ្កួត។

ផ្ទាំងគំនូរតាំងបង្ហាញនៅសារៈមន្ទីរប៉ាស្ទ័រ បន្ទប់ធំសម្រាប់ទទួលទានអាហារ នៅក្នុងគេហដ្ឋានរបស់លោក Louis Pasteur ។

*Source : "Institut Pasteur / Musée Pasteur"*

# Louis Pasteur

រយៈពេលពាក់កណ្តាលចុងក្រោយនៃសតវត្សទី១៩ ត្រូវបានគេសម្គាល់ដោយហេតុការណ៍ចំនួនពីរដែលមិនជាប់ទាក់ទងគ្នាសោះ ប៉ុន្តែជួយបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ទីមួយគឺ បណ្តាប្រទេសនៅអឺរ៉ុបដែលមានបំណងធានាឱ្យបាននូវការបម្រុងទុកវត្ថុធាតុដើម ឬការបើកចំហសេដ្ឋកិច្ច បានបង្កើនការជ្រៀតចូលទៅក្នុងដែនដីតំបន់ត្រូពិកធំៗនៃទ្វីបអាហ្វ្រិក និងអាស៊ី ដែលនាំអ្នកចូលទៅប្រឈមជាមួយជំងឺថ្មីៗ ឯមួយទៀតគឺ លោក *Louis PASTEUR* បានអភិវឌ្ឍការស្រាវជ្រាវរបស់លោកលើប្រភពនៃជំងឺឆ្លង ។

ក្នុងរយៈពេលតែប៉ុន្មានឆ្នាំ ភ្នាក់ងារបង្កជំងឺគ្រុនលាប់បង្កដោយដង្កៅ ជំងឺរាគរូសបង្កដោយព្រូនអាមីប ជំងឺឃ្លង់ ជំងឺអាសន្នរោគ ជំងឺគ្រុនចាញ់ ត្រូវបានស្រាវជ្រាវរកឃើញ និងពណ៌នា។ ថ្នាំបង្ការជំងឺឆ្កែឆ្កួត ត្រូវបានបង្កើតឡើងដោយ *Louis PASTEUR* និង *Emile ROUX* ហើយការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតដំបូង ត្រូវបានធ្វើដោយជោគជ័យនៅខែកក្កដា ឆ្នាំ១៨៨៥។ ដោយសារភាពជោគជ័យដ៏ល្បីរន្ទឺនេះហើយ ទើបវិទ្យាស្ថានប៉ាស្ទ័រ ដែលទទួលបានថវិកាភាគច្រើនតាមរយៈការបង់ថ្លៃ ត្រូវបានសាងសង់ឡើង និងសម្ពោធ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៨៨៨។



# សិស្សរបស់លោកប៉ាស្ទ័រ៖ ដាក់ពង្រាយទៅជុំវិញពិភពលោក

នៅក្នុងរយៈពេលយ៉ាងឆាប់រហ័ស លោក *Louis Pasteur* បានលើកទឹកចិត្តសិស្សរបស់លោកឱ្យធ្វើដំណើរទៅកាន់ទីកន្លែងដែលជំងឺឆ្លងបង្កបញ្ហា។ នៅក្នុងការរីករាលដាលជំងឺនៅប្រទេសអេស៊ីបនៅឆ្នាំ១៨៨៣ ដែលក្នុងអំឡុងពេលនោះ លោក *Robert Koch* បានរកឃើញមេរោគជំងឺអាសន្នរោគ លោក *Louis Pasteur* បានជំរុញកូនសិស្សរបស់លោក ឈ្មោះ *Emile Roux* ឱ្យធ្វើដំណើរទៅកាន់ទីក្រុង *Alexandria* ។ នៅឆ្នាំ១៨៩០ លោក *Albert Calmette* ជាសិស្សនៃវិទ្យាស្ថានប៉ាស្ទ័រ ត្រូវបានលោក *Louis Pasteur* ដាក់បេសកកម្មឱ្យទៅបង្កើតវិទ្យាស្ថានដំបូងគេនៅក្រៅប្រទេសបារាំង៖ វិទ្យាស្ថានប៉ាស្ទ័រ ក្រុងសៃហ្គន (បច្ចុប្បន្ន ក្រុងហូជីមិញ) នៅឆ្នាំ១៨៩១ ។



Source : “Institut Pasteur / Musée Pasteur”

លោក Alexandre Yersin នៅការិយាល័យរបស់លោកនៅញ៉ាត្រាង ឆ្នាំ១៩១០។ នៅខាងក្រោយរូបលោក គឺជាកញ្ចប់បញ្ញើរទៅក្រុមហ៊ុន Michelin

ក្រោយមក ការដាក់ពង្រាយវេជ្ជបណ្ឌិតដែលទទួលបានការបណ្តុះបណ្តាលតាមវិទ្យាសាស្ត្រប៉ាស្ទ័រ មានការកើនឡើង ក្នុងនោះមាន លោក *Charles Nicolle* នៅ ទុយនេស៊ី នៅឆ្នាំ១៨៩៣ (វិទ្យាស្ថានប៉ាស្ទ័រទុយនេស៊ី) *Edmond* និង *Etienne Sergent* នៅអាល់ហ្សេរី នៅឆ្នាំ១៨៩៤ (វិទ្យាស្ថានប៉ាស្ទ័រអាល់ហ្សេរី) *Alexandre Yersin* នៅវៀតណាមនៅឆ្នាំ១៨៩៥ (វិទ្យាស្ថានប៉ាស្ទ័រញ៉ាត្រាង) និង *Emile Marchoux* នៅសេណាហ្គាល់ នៅឆ្នាំ១៨៩៦ (មន្ទីរពិសោធន៍អតិសុខុមសាស្ត្រ *Saint Louis* ដែលបានក្លាយជាវិទ្យាស្ថានប៉ាស្ទ័រដាការ នៅឆ្នាំ១៩២៤)។



*Source : "Institut Pasteur / Musée Pasteur"*

លោក Albert Calmette និងកុមារម៉ាឡេស៊ី
ដែលទទួលបានការបង្ការជំងឺឆ្កែឆ្កួត នៅសៃហ្គន
ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៨៩១។ កុមារទាំងពីរ
នេះ គឺ Ahman និង Kameroodin
ជាកុមារដំបូងគេដែលទទួលការបង្ការជំងឺឆ្កែឆ្កួត
នៅតំបន់អាស៊ី (មិនរាប់បញ្ចូលរុស្ស៊ី)

# អ្នកនាំមុខនៅកម្ពុជា ៖ ១៩១៣-១៩៥២

## ក្រុមអ្នកអ្នកនិយមវិទ្យាសាស្ត្រប៉ាស្ទ័រមានវត្តមាននៅកម្ពុជា នៅមុនពេលបង្កើតវិទ្យាស្ថាន

ចំណាប់អារម្មណ៍របស់វិទ្យាស្ថានប៉ាស្ទ័រនៅប៉ារីស លើស្ថានភាពសុខភាពរបស់ប្រជាជននៅកម្ពុជា មានតាំងពីនៅដើមសតវត្សទី ២០ មកម្លេះ។ នៅដើមឆ្នាំ១៩១០ វេជ្ជបណ្ឌិត *Emile Roux* (ប្រធានវិទ្យាស្ថានប៉ាស្ទ័រនៅពេលនោះ) បានសរសេរលិខិតជូនអគ្គទេសាភិបាលឥណ្ឌូចិន ដើម្បីស្នើថា លោកនឹងបញ្ជូនបេសកកម្មសិក្សាស្រាវជ្រាវមួយ មកកាន់ប្រទេសកម្ពុជា និងឡាវ ដឹកនាំដោយវេជ្ជបណ្ឌិត *Noël Bernard* ។ បេសកកម្មសិក្សានេះ ដែលទទួលបានការគាំទ្រថវិកាពី រដ្ឋាភិបាលទូទៅឥណ្ឌូចិន និងវិទ្យាស្ថានប៉ាស្ទ័រប៉ារីស មានគោលបំណង "សិក្សាអំពីជំងឺឆ្លងលើមនុស្ស ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើប្រទេសកម្ពុជា និងឡាវ និង របៀបឆ្លងនៃជំងឺទាំងនោះ រួមជាមួយការសិក្សាអំពីជំងឺឆ្លងលើសត្វស្រុក"។

នៅក្នុងលិខិតរបស់វេជ្ជបណ្ឌិត *Emile Roux* បានបញ្ជាក់ថា វេជ្ជបណ្ឌិត *Noël Bernard* មិនមែនមកផ្លាស់ប្តូរជំនួសភ្នាក់ងារណាមួយដែលកំពុងតែអនុវត្តសកម្មភាពទៅលើសេវាវេជ្ជសាស្ត្រ និងបសុវេជ្ជសាស្ត្រឡើយ។ ស្របពេលដែលលោកខ្លួនឯងផ្ទាល់ចូលរួមដោះស្រាយទៅលើបញ្ហាអនាម័យ និងការធ្វើរោគវិនិច្ឆ័យគ្លីនិក លោកក៏ត្រូវប្តេជ្ញាដាក់ការប្រឹងប្រែងមួយភាគធំរបស់គាត់ លើការស្រាវជ្រាវពិសោធន៍។ ឯកាធិបតីនៅកម្ពុជា ត្រូវផ្តល់អោយគាត់ នៅរាជធានីភ្នំពេញ នូវទីតាំងសមស្របមួយសម្រាប់ប្រើប្រាស់ នោះគឺបន្ទប់ចំនួន ៤ ឬ ៥ មានគ្រឿងសង្ហារិម តុ ទូ ធ្នើ និងកៅអី ជាសម្ភារៈចាំបាច់ ព្រមទាំងបុគ្គលិកខ្មែរចំនួនពីរនាក់ មានសមត្ថភាពជាជំនួយការរបស់គាត់ ក៏ដូចជា ភ្នាក់ងារសេវាទូទៅម្នាក់ផងដែរ (កាលនោះ មុខងារនេះ គេហៅបែបផ្សេង) ដើម្បីថែទាំសត្វដែលចិញ្ចឹមទុកសម្រាប់ការពិសោធន៍។

ទោះបីជា វេជ្ជបណ្ឌិត *Noël Bernard* មិនទទួលបន្ទុកលើសេវាទូទៅនៅមន្ទីរពេទ្យរាជធានីភ្នំពេញក៏ដោយ ក៏ជាធម្មតាលោកនឹងធ្វើជាអ្នកសហការសម្រាប់វេជ្ជបណ្ឌិតនានា នៅតាមមន្ទីរពេទ្យនេះ ក្នុងការស្រាវជ្រាវអំពីបាក់តេរីសាស្ត្រ សម្រាប់ជាប្រយោជន៍ដល់វេជ្ជបណ្ឌិតទាំងនោះ។ លោកក៏បានអញ្ជើញវេជ្ជបណ្ឌិតនៅតាមខេត្តឱ្យទំនាក់ទំនងមកលោក ហើយជាការណែនាំគឺថា ជាការល្អមួយ បើវេជ្ជបណ្ឌិត *Noël Bernard* អាចរៀបចំអោយមានការពិគ្រោះជំងឺមិនគិតថ្លៃសម្រាប់ប្រជាជនក្នុងស្រុក ដោយមានការសហការណ៍ពីគ្រូពេទ្យជំនួយ និងដោយមានជាមន្ទីរសម្រាកព្យាបាល អាចទទួលអ្នកជំងឺមួយចំនួន ដែលគួរចាប់អារម្មណ៍ធ្វើការតាមដាន។

ឆ្ពោះទៅកិច្ចការនេះ ទើបមានជាបញ្ជីដ៏វែងមួយ រៀបរាប់សម្ភារៈមូលដ្ឋាន ដែលគិតជាទឹកប្រាក់ចំនួន ៤៨៣៣,៩៦ ហ្វ្រង់។ បញ្ជីសម្ភារៈនេះ មិនមានភាពខុសគ្នាពីសារពើភណ្ឌមន្ទីរពិសោធន៍នាពេលបច្ចុប្បន្នទេ បើប្រៀបធៀប ឈ្មោះសម្ភារៈមួយចំនួនបានផ្លាស់ប្តូរ មានព័ត៌មានបន្ថែមតិចតួច ហើយថាមពលអគ្គិសនី និងឧស្ម័នបានជំនួសឱ្យថាមពលប្រើប្រេង។ លិខិតនេះ ពីវេជ្ជបណ្ឌិត *Roux* នៅតែអាចប្រើជាគំរូមួយ សម្រាប់អ្នកណាដែលមានបំណងបង្កើតមន្ទីរពិសោធន៍អនាម័យ និង អេពីដេមីសាស្ត្រ នៅក្នុងតំបន់ត្រូពិក ជាមន្ទីរពិសោធន៍មួយដែលក្រោយមកអាចក្លាយទៅជា វិទ្យាស្ថានប៉ាស្ទ័រ។

ប៉ុន្តែគួរឱ្យសោកស្តាយ ករណីនេះមិនបានកើតឡើងនោះទេ ចំពោះមន្ទីរពិសោធន៍របស់វេជ្ជបណ្ឌិត *Noël Bernard* ។ បន្តិចមុនពេលលោកចាកចេញពីប្រទេសបារាំង តាមដែលវេជ្ជបណ្ឌិត *Yersin* មានប្រសាសន៍ “តាមសំណើរបស់ឯកាធិបតីនៅខេត្តអណ្ណាម និងរបស់អគ្គនាយកសាធារណការ” ទេសាភិបាលឥណ្ឌូចិន បានកែសម្រួលជាបណ្តោះអាសន្ន ការចាត់តាំងវេជ្ជបណ្ឌិត *Bernard* ដោយអោយទៅជួយឯកាធិបតីនៅខេត្តអណ្ណាម សិន ដើម្បីអនុវត្តការងារពិសេស ក្នុងការវិភាគទឹកនៅខេត្តវ៉េ។ វេជ្ជបណ្ឌិត Bernard បានមកដល់ខេត្តវ៉េជាមួយសម្ភារៈបរិក្ខារទាំងអស់ដែលបានគ្រោងទុកសម្រាប់កម្ពុជា ដោយចំណាយថវិការបស់វិទ្យាស្ថានប៉ាស្ទ័រឥណ្ឌូចិន។ លោក *Yersin* បានលើកឡើងថា “វេជ្ជបណ្ឌិត Bernard មិនបានកម្រិតដែនទំនួលខុសត្រូវរបស់លោកត្រឹមការងារវិភាគទឹកនោះទេ លោកក៏បានចូលរួមជួយដល់សេវាសុខាភិបាលមូលដ្ឋានទៅលើការស្រាវជ្រាវបាក់តេរីសាស្ត្រ ដែលមានប្រយោជន៍ដល់អនាម័យសាធារណៈ និងការព្យាបាលអ្នកជំងឺផងដែរ” ។ គួរឱ្យសោកស្តាយសម្រាប់ប្រទេសកម្ពុជា មន្ទីរពិសោធន៍បណ្តោះអាសន្នរបស់វេជ្ជបណ្ឌិត *Bernard* នៅទីក្រុងវ៉េបានក្លាយទៅជាមន្ទីរពិសោធន៍ស្ថាពរមួយនៅទីនោះ។ កាលនោះ ខេត្តវ៉េ គឺជាខេត្តអាសនៈរបស់ស្តេចវៀតណាម។ មន្ទីរពិសោធន៍នេះហាក់បីដូចជាក្លាយទៅជាមន្ទីរពិសោធន៍ពឹងផ្អែកទៅលើវិទ្យាស្ថានប៉ាស្ទ័រប៉ារីស ដោយសារតែមូលហេតុដែលវេជ្ជបណ្ឌិត *Yersin* យល់ថា “មិនមានលក្ខណៈម៉ឺងម៉ាត់ និង យោងទៅតាមផលប្រយោជន៍បុគ្គលដោយឡែក ជាជាងផលប្រយោជន៍ទូទៅសម្រាប់អនាគតរបស់មន្ទីរពិសោធន៍” ។ បន្ទាប់មក មានការពិភាក្សាដេញដោលស្វិតស្វាញរវាង វេជ្ជបណ្ឌិត *Yersin* ជាអ្នកតំណាងវិទ្យាស្ថានប៉ាស្ទ័រប៉ារីសប្រចាំនៅឥណ្ឌូចិន ជាមួយថ្នាក់លើរបស់លោកនៅក្នុងជួរយោធា គឺវេជ្ជបណ្ឌិតអធិការ Clarac ដោយមានមជ្ឈត្តិករជា អគ្គទេសាភិបាលឥណ្ឌូចិន។ ជាចុងក្រោយ តាមសំណើរបស់លោក *Yersin* លោក *Roux* បានសម្រេចបោះបង់បរិក្ខារនៅវិទ្យាស្ថានអនាម័យ និងអេពីដេមីសាស្ត្រ នៅខេត្តវ៉េ និងបញ្ចប់បេសកកម្មរបស់វិទ្យាស្ថានប៉ាស្ទ័រនៅខេត្តវ៉េ ។

ក្នុងរឿងនេះ កម្ពុជាបានបាត់បង់មន្ទីរពិសោធន៍របស់ខ្លួន និងបរិក្ខារដែលត្រូវបានចាត់សម្រាប់ដាក់អោយមន្ទីរពិសោធន៍នោះ។ លិខិតពីវេជ្ជបណ្ឌិត *Yersin* ពីឆ្នាំ១៩១២ ទៅឯកាធិបតីនៅកម្ពុជា មានបំណងរៀបចំជាថ្មីទៀតនូវបេសកម្មប៉ាស្ទ័រមកកាន់កម្ពុជា ប៉ុន្តែបំណងនោះមិនបានជោគជ័យនោះទេ។ វេជ្ជ-បណ្ឌិត Bernard បានត្រលប់ទៅកាន់ប្រទេស

បារាំងវិញនៅឆ្នាំ១៩១៤ ជាពេលដែលសង្គ្រាមលោកលើកទីមួយទើបតែចាប់ផ្ដើម។ ប៉ុន្ដែកម្ពុជាមិនមែនមិនមានមន្ទីរពិសោធន៍សោះនោះទេ ៖ នៅឆ្នាំ ១៩១៣ វេជ្ជបណ្ឌិត *Jean-François Kérandel* និស្សិតចេញពីវគ្គបណ្ដុះបណ្ដាលប៉ាស្ទ័រ បានបង្កើតមន្ទីរពិសោធន៍អតិសុខុមសាស្ដ្រមួយនៅរាជធានីភ្នំពេញ។ ការស្រាវជ្រាវរបស់លោក ផ្ដោតលើជំងឺប៉េស្ដគោ ក្របី ដែលវាយលុកនៅក្នុងតំបន់ និងធ្វើអោយថយចុះការផលិត និងការនាំចេញបសុសត្វក្នុងស្រុក។ ជាចុងក្រោយ វេជ្ជបណ្ឌិត *Noël Bernard* ដដែលនោះ ដែលស្របពេលជាមួយគ្នានោះបានក្លាយជាប្រធានវិទ្យាស្ថានប៉ាស្ទ័រសៃហ្គន បានមកបំពេញបេសកកម្មនៅរាជធានីភ្នំពេញ នៅឆ្នាំ១៩២៣ ដើម្បីសិក្សាអំពីជំងឺប៉េស្ដលើមនុស្ស ដែលលោកបានអនុវត្តជាមួយវេជ្ជបណ្ឌិត *Menaut* ជាប្រធានសេវាអនាម័យកម្ពុជា និងវេជ្ជបណ្ឌិត Simon ជាប្រធានមន្ទីរពិសោធន៍អតិសុខុមសាស្ដ្រកម្ពុជា (មិនមែនជាលោក *Paul-Louis Simond* ដែលគេស្គាល់នៅប្រទេសឥណ្ឌាតាមរយៈការរកឃើញតួនាទីនៃសត្វចៃ ក្នុងការចម្លងជំងឺប៉េស្ដ ដោយលោក *Paul-Louis Simond* បានចូលនិវត្តន៍នៅទីក្រុងវ៉ាឡង់អស់រយៈពេលដប់ឆ្នាំមកហើយ) ។

នៅឆ្នាំ១៩៤៦ វិទ្យាស្ថានប៉ាស្ទ័រញ៉ាត្រាង នៅប្រទេសវៀតណាម ដែលប៉ះពាល់ដោយព្រឹត្តិការណ៍សង្គ្រាមលោកលើកទីពីរ បានសម្រេចបង្កើតជាបណ្ដោះអាសន្ននូវសាខាបសុវេជ្ជសាស្ដ្របន្ថែមមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផលិតថ្នាំបង្ការជំងឺប៉េស្ដគោ ក្របី ។ “មន្ទីរពិសោធន៍បសុវេជ្ជសាស្ដ្រភ្នំពេញ” ដឹកនាំដោយបសុវេជ្ជបណ្ឌិត *Jacques Vittoz* បានបើកដំណើរការនៅខែសីហា ឆ្នាំ ១៩៤៦ ។ ទីតាំងដែលបានជ្រើសរើស ស្ថិតនៅក្រៅក្រុង ក្នុងឧទ្យានចត្តាឡីស័កសម្រាប់ការនាំចេញគោក្របី នៅឯចុងជ្រោយចង្វារ ជាជ្រោយនៅរវាងទន្លេមេគង្គ និងទន្លេសាប ចំខាងមុខព្រះបរមរាជវាំង។ នៅពេលនោះហេដ្ឋារចនាសម្ព័ន្ធរួមមានត្រឹមតែប៉ុន្មានក្រោលសត្វប៉ុណ្ណោះ ។

ផលិតកម្មមានរយៈពេលខ្លីប៉ុណ្ណោះ ដោយសារតែមន្ទីរពិសោធន៍ដ៏ធំនៅញ៉ាត្រាង ត្រូវបានបើកដំណើរការវិញនៅឆ្នាំ១៩៤៧ ហើយនៅថ្ងៃទី១៧ ខែមេសា គម្រោងនៅកម្ពុជា គឺត្រូវបានផ្អាក។ កិច្ចសន្យាមួយត្រូវបានចុះហត្ថលេខា នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៤៨ រវាងក្រសួងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ជាមួយ វិទ្យាស្ថានប៉ាស្ទ័រញ៉ាត្រាង លើការផ្គត់ផ្គង់ថ្នាំបង្ការ និងសេរ៉ូម សម្រាប់បសុសត្វ ។

*ក្រោយពីអាក់ខានអស់រយៈពេល ១៨ ខែមក ការផលិតថ្នាំបង្ការជំងឺប៉េស្ដគោ ក្របី ត្រូវបានចាប់ផ្ដើមជាថ្មីឡើងវិញនៅឆ្នាំ១៩៤៨ ជាមួយការមកដល់របស់បសុវេជ្ជបណ្ឌិត **Yves Goueffon** និងឥណទានស្មើនឹងប្រាំលានហ្វ្រង់ ពីឧត្ដមស្នងការបារាំងប្រចាំនៅសៃហ្គន។ ក្នុងរយៈពេលបួនឆ្នាំ (១៩៤៩-១៩៥២) ការផលិតថ្នាំបង្ការជំងឺប៉េស្ដ គោ ក្របី កើនឡើង និងអនុញ្ញាតឱ្យមានការបង្ការជំងឺនេះប្រកបដោយប្រសិទ្ធភាពបំផុត នៅក្នុងប្រទេសកម្ពុជា ។*




ខ្លោងទ្វារ វិទ្យាស្ថានប៉ាស្ទ័រ
កម្ពុជា នៅជ្រោយចង្វារ
(ឆ្នាំ១៩៥៣)

Source : “Institut Pasteur / Musée Pasteur”

# ១៩៥៣-១៩៧៥
# វិទ្យាស្ថានប៉ាស្ទ័រនៅជ្រោយចង្វារ

# ១៩៥៣ ៖ ការបង្កើត និង ការសម្ពោធ

*ឯករាជ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៥៣ បាននាំឱ្យមានការញែកដាច់ពីគ្នា រវាងវិទ្យាស្ថានញ៉ាត្រាង និង វិទ្យាស្ថានសាខារបស់ខ្លួននៅរាជធានីភ្នំពេញ។*

តាមរយៈគំនិតផ្តួចផ្តើមរបស់បសុវេជ្ជបណ្ឌិត *Maurice Huard Surgeon* កិច្ចសន្យាដំបូងមួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៥៣ រវាង វិទ្យាស្ថានប៉ាស្ទ័រប៉ារីស (វេជ្ជបណ្ឌិត *Henri Marneffe* តំណាងវិទ្យាស្ថានប៉ាស្ទ័រនៅឥណ្ឌូចិន) និង រាជរដ្ឋាភិបាលកម្ពុជា (លោក ដាញ់ ស្ងួង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ) ដែលបានទទួលស្គាល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុរបស់វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ ដែលជាវិទ្យាស្ថានបុត្រសម្ព័ន្ធរបស់វិទ្យាស្ថានប៉ាស្ទ័រប៉ារីស។

**ការសម្ពោធជាផ្លូវការនៃ វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ បានប្រព្រឹត្តទៅនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៥៣** លើទីតាំងដើមនៃមន្ទីរពិសោធន៍បសុវេជ្ជសាស្ត្រជ្រោយចង្វារ ក្រោមវត្តមានឥស្សរជនជាន់ខ្ពស់ទាំងកម្ពុជា និងបារាំង ។

នៅក្នុងសុន្ទរកថារបស់លោក បន្ទាប់ពីបានរំឭកអំពីតួនាទីរបស់អ្នកដឹកនាំស្ថាប័នមុនលោកគឺលោកបណ្ឌិត *Genevray* ស្ថាបនិកចម្បងនៃវិទ្យាស្ថាននេះ លោកវេជ្ជបណ្ឌិត *Marneffe* បានគ្រោងនឹងពង្រីកការផលិតថ្នាំបង្ការបសុវេជ្ជសាស្ត្រផ្សេងៗឱ្យបានកាន់តែច្រើនប្រភេទថែមទៀត នៅវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ។ គាត់ក៏បានគិតទៅដល់ ការផ្តល់លទ្ធភាពកាន់តែច្រើន ដល់ការធ្វើតេស្តរកការឆ្លងជំងឺ និងប៉ារ៉ាសិត លើសត្វ ព្រមទាំងការចូលរួមក្នុងការបង្រៀនផ្នែកជីវវិទ្យានៅសាលាបសុវេជ្ជសាស្ត្រភ្នំពេញផងដែរ។ លោកបានបញ្ជាក់ថា៖

> **“វិសាលភាពបេសកកម្មនេះ និងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានមកពីបេសកកម្មនេះ នាំអោយ វិទ្យាស្ថានប៉ាស្ទ័រ ទទួលបាននូវទំនុកចិត្ត”។**

កម្មវិធីនេះ ត្រូវបានកំណត់ដូចខាងក្រោម ដោយពាក្យស្លោកសម្រាប់អនុវត្តជាពាក្យរបស់លោក *Louis Pasteur* ពោលគឺ បម្រើ។ បេសកកម្មរបស់វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ គឺមិននៅត្រឹមតែជួយដល់អ្នកជំងឺប៉ុណ្ណោះទេ។ បម្រើ នឹងបានដល់ការជួយអោយប្រជាជាតិកម្ពុជាបោះជំហានទៅរកវិបុលភាព [...]។ ផ្តល់នូវការផ្សព្វផ្សាយកាន់តែទូលំទូលាយអំពីវិស័យនិងបច្ចេកទេសជីវវិទ្យា ពង្រីកសេចក្តីស្រឡាញ់ដោយមិនគិតអំពីផលប្រយោជន៍ចំពោះការសង្កេត និងការស្រាវជ្រាវវិទ្យាសាស្ត្រ៖ ពោលគឺប្រើប្រាស់ និង ណែនាំអោយដឹងពីធនធានវិទ្យាសាស្ត្រនានា ក្នុងកិច្ចជាប្រយោជន៍ និងស្ថាបនា”។

*ឯកឧត្តម យ៉េម សំបូរ* រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ តំណាងឱ្យរាជរដ្ឋាភិបាល បានឆ្លើយតបដោយរំឭកគុណានុបការៈរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងនៃ វិទ្យាស្ថានប៉ាស្ទ័រប៉ារីស ចំពោះជំនួយដ៏មានតម្លៃដែលបានផ្តល់ជូនព្រះរាជាណាចក្រកម្ពុជា ដើម្បីផលិតថ្នាំបង្ការជំងឺប៉េស្ត នៅក្នុងស្ថានភាពដ៏លំបាក។ លោករដ្ឋមន្ត្រីបានធ្វើការធានាចំពោះអ្នកតំណាងរបស់ វិទ្យាស្ថានប៉ាស្ទ័រ អំពីការយកចិត្តទុកដាក់របស់លោកផ្ទាល់ និងការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ថា “... គឺដើម្បីអោយស្នាដៃវិទ្យាសាស្ត្រនេះ រស់រាន និង បន្តរីកលូតលាស់នៅលើទឹកដីកម្ពុជា ជាប្រយោជន៍សម្រាប់ប្រជាជន និងសម្រាប់កេរ្តិ៍ឈ្មោះរបស់លោកប៉ាស្ទ័រ។ លោកក៏បានបង្ហាញក្នុងសុន្ទរកថារបស់លោកអំពីផែនការ សាងសង់វិទ្យាស្ថានថ្មីមួយនៅជិតរាជធានីភ្នំពេញ ហើយវេជ្ជបណ្ឌិត *Maurice Huard* ប្រធានវិទ្យាស្ថាន ក៏បានបញ្ជាក់ដែរ តាមរយៈការសម្ភាសន៍ជាមួយសារព័ត៌មានថា បានគ្រោងនឹងសាងសង់វិទ្យាស្ថានថ្មីនៅក្បែរសាលាកសិកម្ម និង កសិដ្ឋាន នៅ “តាកែវតូច”។ ទើបនឹងបង្កើតឡើងមិនទាន់បានប៉ុន្មានផង វិទ្យាស្ថានរបស់យើងហាក់ពោរពេញទៅដោយគម្រោងជាច្រើន ចំណែកទីតាំងនៅជ្រោយចង្វារ គឺនៅរក្សាទុកដដែលសម្រាប់រយៈពេលយ៉ាងតិចក៏ ២០ឆ្នាំទៀត ។

វេជ្ជបណ្ឌិត *Maurice Huard* បានក្លាយជាប្រធានដំបូងរបស់វិទ្យាស្ថាន ។ មន្ទីរពិសោធន៍នៃ វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ ត្រូវបានដាក់ដំណើរការបម្រើអោយរដ្ឋាភិបាលកម្ពុជា និងប្រធានរដ្ឋបាលតំបន់នានា សម្រាប់ការសិក្សាការស្រាវជ្រាវ និងការវិភាគទាំងអស់ដែលទាមទារជំនាញអតិសុខុមសាស្ត្រ សម្រាប់ការបង្ការជំងឺឆ្លងពីសត្វ និង ឆ្លើយតបទៅការស្នើសុំរបស់សេវាបសុវេជ្ជសាស្ត្រ។ វិទ្យាស្ថានប៉ាស្ទ័រអនុវត្តក្នុងផ្ទៃប្រទេសកម្ពុជា នូវបេសកកម្មអង្កេតនិងសិក្សាអតិសុខុមសាស្ត្រ ដែលបានស្នើសុំដោយសេវាបសុវេជ្ជសាស្ត្រ។ វិទ្យាស្ថាន ក៏ផ្តល់ជូនដែរនូវការបណ្តុះបណ្តាលបច្ចេកទេសការអប់រំបន្ថែម និង ការបណ្តុះបណ្តាលជាន់ខ្ពស់សម្រាប់បុគ្គលិកសេវាបសុវេជ្ជសាស្ត្រ និងសាលាកសិកម្ម។ ផលិតផលនានាផ្សេងទៀតក្នុងគោលដៅបង្ការជំងឺលើមនុស្ស និងលើសត្វគោក្របីដែលស្នើសុំដោយរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់ជូនក្នុងរយៈពេលដំបូង ដោយវិទ្យាស្ថានប៉ាស្ទ័រប៉ារីស (ថ្នាំបង្ការ និងសេរ៉ូមប្រឆាំងនឹងជំងឺអង់ត្រាក់ ជំងឺជ្រូកត្រចៀកខៀវ ជំងឺរូហេ្ស ជំងឺលើសត្វមាន់ទា និងថ្នាំបង្ការជំងឺឆ្កែឆ្កួតលើមនុស្ស) ។

*ដោយមានទីតាំងស្ថិតនៅបរិវេណអំណោយផល និងថែទាំបានល្អ បន្ទាប់មកវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ ត្រូវបានដាក់ចូលក្នុងវង់ដំណើរទស្សនៈកិច្ចផ្លូវការនានារបស់ទីក្រុង និងទទួលបាននូវការលើកសរសើរពីសំណាក់ភ្ញៀវកិត្តយស សម្រាប់តំបន់ជ្រោយចង្វារ។*

នៅក្នុងទស្សនាវដ្ដីរូបភាពឈ្មោះ “កម្ពុជា” ឬ “Cambodge” ចុះផ្សាយខែមេសា ឆ្នាំ ១៩៥៤ លោក Audière ជាអ្នកសារព័ត៌មានដែលបានធ្វើទស្សនកិច្ច បានសរសេរអត្ថបទមួយអំពីវិទ្យាស្ថាននេះ ដែលកាលនោះមានបុគ្គលិកចំនួន ៤៣ នាក់ បំពេញការងារ រួមទាំងប្រធានវិទ្យាស្ថាន និង អ្នកសេដ្ឋកិច្ចម្នាក់ ផង ។

*“មានមនុស្សតិចតួចណាស់ប្រថុយជិះកូនទូកមកទស្សកិច្ចនៅត្រើយជ្រោយចង្វារ។ ទោះយ៉ាងណា អ្នកចូលចិត្តរឿងព្រេងនិទានជាពិសេសភាពស្ងប់ស្ងាត់បែបជនបទ អាចមើលឃើញជីវភាពនៅទីនោះ ទល់មុខរាជធានីនៃប្រទេសកម្ពុជា ក្នុងប្រជុំភូមិបណ្ដែតទឹក និងក្រុមទូកអ្នកនេសាទ ដូចជា ជាងស្មូនធ្វើពាងអ្នកធ្វើនំបញ្ចុកហាលម្សៅពណ៌សភ្លឺផ្លេកក្រោមពន្លឺព្រះអាទិត្យ អ្នកជ្រលក់ពណ៌លាតហាលក្រណាត់ជ្រលក់ពណ៌រួចនៅលើស្មៅពណ៌បៃតង។ គឺនៅកណ្ដាលសហគមន៍សិប្បករក្បែរវត្តដ៏ស្រស់ស្អាតមួយ ប្រកបដោយម្លប់ពីដើមជ្រៃដ៏ធំៗ បែបនេះហើយ ដែលវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ ស្ថិតនៅ។ សូមស្រមៃទៅមើល! ទីកន្លែងមួយប្រៀបបានទីស្នាក់អាស្រ័យពោរពេញដោយភាពសារស្វាគមន៍ ជាមួយម្ហូបអាហារមានអនាម័យយ៉ាងម៉ត់ចត់ ជាទីដែលសុភាពនារីក្មេងៗ ពាក់គម្របសក់ពណ៌សក្បុស ច្រកសារធាតុរាវចូលក្នុងដបដែលមានបិតស្លាកថាវបាយមេ” ។*

*ប៉ុន្តែ បន្ទាប់ពីបានឆ្លងកាត់ផ្លូវលំដែលមានម្លប់ត្រឈឹងត្រឈៃពីដើមផ្កាក្រោក អមសងខាងដោយសួនផ្កាកូឡាបដ៏ស្រស់ស្អាត គាត់អាចមើលឃើញទ្រុងសត្វមួយជួរដែលនៅក្នុងនោះមានសត្វគោកំពុងទំពារស៊ីអំពៅ។ ជារៀងរាល់សប្ដាហ៍ គេចាប់គោទាំងនោះ ដាក់អោយដេកលើតុទម្រមួយ ហើយបូមយកឈាម ២ ទៅ ៣ លីត្រ ដើម្បីរៀបចំផលិតជាសេរ៉ូមបង្ការនិងព្យាបាលជំងឺ ។ បន្ទាប់មក គាត់ចូលដល់ក្នុង “បរិវេណក្រោលសត្វសម្រាប់ទទួលថ្នាំបង្ការ” ជាកន្លែងរក្សាកូនគោប្រមាណមួយរយក្បាលមកដល់ដោយហែលទឹក សម្រាប់ជាវត្ថុធាតុដើមផលិតថ្នាំបង្ការ។ បន្ទាប់មក គឺជាបន្ទប់បិទយ៉ាងជិតល្អសម្រាប់ផ្ទេរវីរុស បន្ទប់យកឈាម ព្រមទាំងបន្ទប់សត្តឃាត ។ដើម្បីចាកចេញពីបន្ទប់បិទជិតដែលមានសត្វឆ្លងមេរោគ គេត្រូវរម្ងាប់មេរោគនៅជើងដោយដើរជាន់ក្នុងថាសមានដាក់ទឹករម្ងាប់មេរោគ។ តទៅទៀត បន្ទាប់ពីបន្ទប់រម្ងាប់មេរោគដែលមានម៉ាស៊ីនចំហុយរម្ងាប់មេរោគធំៗជាច្រើន ដំណើរទស្សនកិច្ចបញ្ចប់ដោយការឆ្លងកាត់ទីកន្លែងផ្សេងៗទៀត រួមមាន រោងជាង រោងបោកគក់ បន្ទប់វេចខ្ចប់ថ្នាំបង្ការ បន្ទប់សម្លៀកបំពាក់ និង បន្ទប់ផ្លាស់ប្ដូរសម្លៀកបំពាក់។ ប្រធានវិទ្យាស្ថាន ចង់បន្តពន្យល់ប្រាប់ខ្ញុំអោយច្បាស់អំពីរឿងផ្សេងៗទៀត ក៏ដូចជាគម្រោងរបស់លោកក្នុងការបង្កើតវិទ្យាស្ថានមួយ ធំទំនើប នៅក្នុងរាជធានីភ្នំពេញផ្ទាល់តែម្ដង ប៉ុន្តែខណៈនោះ បុគ្គលិករបស់គាត់សុំអោយគាត់ទៅជួយ... »។ គម្រោងវិទ្យាស្ថានថ្មីនេះ ក៏សម្រេចបាននៅរយៈពេល ៤០ ឆ្នាំក្រោយ !*

# ឆ្នាំ ១៩៥៤-១៩៥៧

*រវាងឆ្នាំ១៩៥៤ និងឆ្នាំ១៩៥៧ វិទ្យាស្ថានរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយគ្រាន់តែការផលិតថ្នាំបង្ការជំងឺប៉េស្តតែមួយមុខ ត្រូវបន្ថែមការរៀបចំជីវសាស្ត្រថ្មីៗសម្រាប់ការប្រើប្រាស់ទាំងលើមនុស្ស និងទាំងលើសត្វ ដូចជាប្រឆាំងជំងឺឆ្កែឆ្កួត ជំងឺអុតគោ និងជំងឺសារទឹក ។*

នៅឆ្នាំ១៩៥៥ *វេជ្ជបណ្ឌិត* *René Triau* ជាបសុវេជ្ជបណ្ឌិត និង វេជ្ជបណ្ឌិត បានបន្តតំណែងពី*វេជ្ជបណ្ឌិត* *Maurice Huard* ជាប្រធានវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ។ នៅក្នុងឆ្នាំដដែលនោះ មន្ទីរពិសោធន៍ថ្នាំបង្ការជំងឺអុតធំសម្រាប់ប្រើលើមនុស្ស ត្រូវបានបង្កើតឡើង ចំណែកការផលិតថ្នាំបង្ការជំងឺសារទឹក ជំងឺឈាមខ្មៅមានរោគសញ្ញាបង្កដោយបាក់តេរី ជំងឺឆ្កែឆ្កួត និងជំងឺអាសន្នរោគបក្សី ក៏បានចាប់ផ្តើម ។



Source : “Institut Pasteur / Musée Pasteur”

*ការប្រមូលឈាមគោដែលបានចាក់ថ្នាំបង្ការរួច សម្រាប់ការរៀបចំផលិតជាសេរ៉ូមប្រឆាំងមេរោគ (ឆ្នាំ១៩៥៥)*

ការបិទច្រកព្រំដែនវៀតណាម ជាហេតុនាំអោយ វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ រៀបចំតម្កល់ផលិតផលជីវសាស្ត្រនៅឯ វិទ្យាស្ថានប៉ាស្ទ័រប៉ារីស។ កាលពីមុន កម្ពុជាស្តុកទុកសេរ៉ូម និងថ្នាំបង្ការនៅសៃហ្គន ។

នៅឆ្នាំ១៩៥៦ គេឃើញមានការបង្កើតមន្ទីរពិសោធន៍បង្កក-សម្ងួត សម្រាប់ការផលិតថ្នាំបង្ការរក្សាទុកតាមរយៈការសម្ងួត។ ថ្នាំបង្ការថ្មីប្រភេទស្ងួត ប្រឆាំងជំងឺប៉េស្តគោ ក្របី ត្រូវបានផលិតឡើង ក៏ដូចជាថ្នាំបង្ការស្ងួតប្រឆាំងជំងឺអុតធំ និងថ្នាំបង្ការជំងឺឆ្កែឆ្កួតលើមនុស្ស (ផលិតបាន ២ ៧៧៧ ១៨០ ដូស ក្នុងឆ្នាំ១៩៥៧)។ នៅក្នុងរវាងរយៈពេលប៉ុន្មានឆ្នាំ ថ្នាំបង្ការទាំងអស់ដែលចាំបាច់សម្រាប់ការការពារបសុសត្វកម្ពុជា ត្រូវបានផលិតឡើង ហើយមួយមុខៗក្នុងបរិមាណគ្រប់គ្រាន់ ។



Source : “Institut Pasteur / Musée Pasteur”

*ក្រោលរបស់សត្វគោដែលគេរក្សាសម្រាប់ការរៀបចំផលិតសេរ៉ូមប្រឆាំងជំងឺប៉េស្តលើសត្វ (ឆ្នាំ១៩៥៥)*

នៅឆ្នាំ១៩៥៧ មន្ទីរពិសោធន៍ជំងឺអាសន្នរោគមនុស្ស មន្ទីរពិសោធន៍កំណាស៊ុតសម្រាប់ការរៀបចំផលិតថ្នាំបង្ការដោយប្រើប្រាស់ស៊ុតករកូន និង មន្ទីរពិសោធន៍រូប-គីមីសាស្ត្រ ត្រូវបានបើកដំណើរការ ស្របពេលដែលកសិដ្ឋានចិញ្ចឹមមាន់ទាធំមួយបានបង្កើតឡើង ។



*សួនច្បារ និង អគារធំ នៃអតីតវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅរាជធានីភ្នំពេញ ឯជ្រោយចង្វារ ឆ្នាំ១៩៦០*

*Source : “Institut Pasteur / Musée Pasteur”*

# ១៩៥៨ ៖ វិទ្យាស្ថានក្លាយជា វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

នៅខែមករា ឆ្នាំ១៩៥៨ អង្គភាពនេះ មានឈ្មោះជា វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។ កិច្ចសន្យារយៈពេលដប់ឆ្នាំរវាងរាជរដ្ឋាភិបាលកម្ពុជា និងវិទ្យាស្ថានប៉ាស្ទ័រប៉ារីស បានត្រូវចុះហត្ថលេខាជាផ្លូវការនៅ **ថ្ងៃទី ២០ ខែមេសា ឆ្នាំ១៩៥៨** រវាងប្រធានគណៈរដ្ឋមន្ត្រី លោក ប៉ែន នុត និងប្រធានវិទ្យាស្ថានប៉ាស្ទ័រប៉ារីស បណ្ឌិត *Jacques Tréfouel* ។ មន្ទីរពិសោធន៍ ក៏បានតម្រង់ទិសការងារទៅរកជីវវិទ្យា និងពេទសាស្ត្រមនុស្ស ។

កិច្ចសន្យាថ្មីនេះ ដែលចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៨ ពណ៌នាផែនសកម្មភាពផ្នែកជីវវិទ្យាមនុស្ស៖ (i) ការផលិតថ្នាំបង្ការជំងឺគ្រុនពោះវៀន (ii) ថ្នាំបង្ការជំងឺប៉េស្តមនុស្ស (iii) ការបង្កើតមន្ទីរពិសោធន៍វិភាគជាលិកា (iii) ការដាក់ឱ្យដំណើរការបច្ចេកទេសបណ្តុះជាលិការស់សម្រាប់ការសិក្សាផ្នែកវីរុសសាស្ត្រ ។

*Source : “Institut Pasteur / Musée Pasteur”*

*គម្រោងការនៃការដំឡើងវិទ្យាស្ថានប៉ាស្ទ័រ ប្រទេសកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំ ១៩៥៩ ។*

## PLAN DES INSTALLATIONS AU 31 DECEMBRE 1958

1 Ponton
2 Accès au ponton
3 Cabine de transformation
4 Conciergerie
5 Bungalow du directeur
6 Elevage des lapins et souris
7 Animalerie
8 Microbiologie
9 Buanderie
10 Chimie
11 Stérilisation laverie
12 Service des vaccins
13 Magasin aux essences
14 Poulailler
15 Elevage des poussins
16 Menuiserie
17 Atelier mécanique
18 Fumière
19 Four crématoire
20 Salle autopsie
21 Atelier alimentation
22 Douches - vestiaire
23 Charnier
24 Magasins généraux
25 Grands animaux inoculés
26 Singerie
27 Elevages en batteries
28 Incubation artificielle
29 Parquets de jeunes volailles (1.000)
30 Poulaillers (700 x 3 volailles)
31 Service des virus
32 Logement chef de laboratoire
33 Parc d'élevage
34 Plantation
35 Fosse à serpents
36 Cobayeraie - lapinière




INSTITUT PASTEUR

# ឆ្នាំ ១៩៦១-១៩៦៩

***នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៦០ វេជ្ជបណ្ឌិត Yves Goueffon បានបន្តតំណែងពីលោកវេជ្ជបណ្ឌិត René Triau ជាប្រធានវិទ្យាស្ថាន ដែលពេលនោះមានបុគ្គលិកចំនួន ១០៦ នាក់។ លោកបានកាន់តំណែងនេះរហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។***

បន្ទាប់ពីឆ្លងកាត់បញ្ហាលំបាកជាច្រើនរហូតដល់ឆ្នាំ១៩៦០ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ទទួលបាននូវការរីកចម្រើនដោយសុខដុម និងប្រកបទៅដោយផ្លែផ្កា។ ស្ថានភាពបានល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ ជាពិសេសដោយសារតែមានជំនួយពីបារាំង ក្នុងរូបភាពជាសម្ភារៈបរិក្ខារ និង ចំណាយហិរញ្ញវត្ថុ សម្រាប់ប្រធានមន្ទីរពិសោធន៍ ចំនួនប្រាំរូប ដែលជាអ្នកជំនាញការមកពី ផ្នែកសហប្រតិបត្តិការបច្ចេកទេស។ ទាំងនេះបាននាំឱ្យមានការរៀបចំជាមន្ទីរពិសោធន៍ថ្មីៗទៀត បណ្ណាល័យ និង កន្លែងចិញ្ចឹមសត្វកណ្ដុរ ជាដើម ។ ដូចនេះ ការអនុវត្តកម្មវិធីការស្រាវជ្រាវនិងអង្កេតមួយ ព្រមជាមួយមន្ទីរពិសោធន៍ថ្មីៗ បានចាប់ផ្ដើមឡើង ។

ដោយនៅតែរក្សាសកម្មភាពផលិតថ្នាំបង្ការប្រើលើសត្វ និងលើមនុស្ស ដែលចាំបាច់សម្រាប់ប្រើនៅក្នុងប្រទេសកម្ពុជា វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានចាប់អារម្មណ៍កាន់តែច្រើនឡើងលើរោគសាស្ត្រមនុស្ស ។

នៅឆ្នាំ១៩៦១ *វេជ្ជបណ្ឌិត Claude Chastel* បានបង្កើតផ្នែកវីរុសសាស្ត្រទាក់ទងនិងមនុស្ស ដែលជាមន្ទីរពិសោធន៍ អាកបូវីរុស (arbovirus) ដំបូងគេ នៅក្រៅប្រទេសបារាំង ដើម្បីអនុវត្តការស្រាវជ្រាវប្រភេទនេះ និងទាញយកលទ្ធផលវិទ្យាសាស្ត្រថ្មីៗ។ មិនយូរប៉ុន្មាន មន្ទីរពិសោធន៍នេះ ក៏បានរកឃើញ **វីរុសគ្រុនឈឺក** (១៩៦១) ប្រភេទវីរុសគ្រុនឈាមផ្សេងៗ (១៩៦២) និង វីរុស **Getha** ព្រមជាមួយ វីរុសរលាកខួរក្បាល **Japanese encephalitis** (១៩៦៦)។ ការបោះពុម្ពផ្សាយអត្ថបទវិទ្យាសាស្ត្រជាច្រើនបានមកពីការងារស៊ីជម្រៅដំបូងទាំងនេះ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ *វេជ្ជបណ្ឌិត Claude Chastel* ក៏បានសិក្សាលើវីរុសជំងឺគ្រុនស្វិតដៃជើង និង ជំងឺឆ្កែឆ្កួតលើមនុស្សផងដែរ។ ក្រោយមក ផ្នែកវីរុសសាស្ត្រ ក៏ចាប់អារម្មណ៍លើបញ្ហាគ្រុនស្វិតដៃជើង និង បញ្ហាជំងឺឆ្កែឆ្កួតលើមនុស្ស ហើយថ្នាំបង្ការមួយសម្រាប់ជំងឺឆ្កែឆ្កួតនេះ ត្រូវបានផលិតដោយវិទ្យាស្ថាន ។ វិទ្យាស្ថានប៉ាស្ទ័រក៏បានរៀបចំផលិត និង គ្រប់គ្រងថ្នាំបង្ការជំងឺអុតធំ ជាថ្នាំបង្ការដែលបានចូលរួមចំណែកយ៉ាងធំធេងក្នុងការលុបបំបាត់ជំងឺអុតធំនៅក្នុងផ្នែកនេះនៃពិភពលោក ។



*បុគ្គលិកនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា*
*នៅជ្រោយចង្វារ (ឆ្នាំ១៩៦០)*

*Source : “Institut Pasteur / Musée Pasteur”*

មន្ទីរពិសោធន៍បាណកសាស្រ្តមួយ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៧ ដោយ *វេជ្ជបណ្ឌិត Klein* មកពី ORSTOM (ក្លាយជា IRD) ដើម្បីសិក្សាអំពីពពួកសត្វល្អិតដែលបឺតឈាម មានសារៈសំខាន់ក្នុងវេជ្ជសាស្រ្ត និងបសុវេជ្ជសាស្រ្ត អំពីការឆ្លងមេរោគក្នុងខ្លួននិងការចម្លងមេរោគចេញពីក្នុងខ្លួនរបស់ពួកវា  ក៏ដូចជា អំពីវដ្តនៃការចម្លងរោគរបស់ពួកវា ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយផ្នែកវីរុសសាស្រ្ត ។

ដោយមានបរិក្ខារទំនើបនិងមានប្រសិទ្ធិភាពផ្នែកវិភាគគីមីពហុមុខងារមួយ បានចាប់ផ្តើមដំណើរការបម្រើអោយវិស័យសេដ្ឋកិច្ចកម្ពុជា ដោយការវិភាគទឹកមើលទៅលើលក្ខណៈធម្មជាតិ និងសមាសធាតុរបស់ទឹក សម្រាប់បម្រើបម្រាស់ផ្នែកឧស្សាហកម្ម ផ្នែកគីមីឧស្សាហកម្ម និងឱសថសាស្រ្ត ដោយការវិភាគប្រូម សម្រាប់ផ្ទៀងផ្ទាត់គុណភាពទីផ្សារ ភាពមិនសុទ្ធ និងកម្រិតជាតិពុល របស់ផលិតផលនានា។

ជាឧទាហរណ៍ កាលនោះ មន្ទីរពិសោធន៍នេះ បានរកឃើញនៅក្នុងខេត្តរតនគិរី នូវវត្តមានទឹកដែលមានសមាសធាតុខនិជ ស្រដៀងគ្នាទៅនឹងទឹក Evian ។ មន្ទីរពិសោធន៍នេះ ក៏បានរកឃើញការក្លែងបន្លំធូន់ធ្ងរមួយចំនួន ។ ដូច្នេះ ប្រេងគ្រាប់លិន (huile de lin) ដែលមកពីប្រទេសអង់គ្លេសឆ្លងកាត់តាមប្រទេសសិង្ហបុរី ត្រូវបានរកឃើញថាមានបន្លំលាយប្រេងរ៉ៃ ក្នុងកម្រិត ៤0% ជាហេតុធ្វើឲ្យប្រេងនេះមិនអាចប្រើប្រាស់បានសម្រាប់ការផលិតថ្នាំពណ៌។ ដូចគ្នានេះដែរ តាមរយៈការត្រួតពិនិត្យនំសណ្តែកដីសម្រាប់ការនាំចេញ គេបានរកឃើញមានជាតិអាផ្លាតុកស៊ីន ជាជាតិពុលលើថ្លើម  ដែលគេហាមប្រើប្រាស់នៅក្នុងចំណីអាហារ។









*ការពិនិត្យដោយមីក្រូទស្សន៍*
*មន្ទីរពិសោធន៍ (១៩៦០)*

*Source : "Institut Pasteur / Musée Pasteur"*

មន្ទីរពិសោធន៍គីមីវេជ្ជសាស្ត្រ បង្កើតឡើងក្នុងឆ្នាំ១៩៦២ នឹងរ៉ាប់រងធ្វើវិភាគជីវវេជ្ជសាស្ត្រទូទៅ ក៏ដូចជាវិភាគលើវ៉ាក់សាំង (*បសុវេជ្ជបណ្ឌិត ស្រី ថូន ជាជីវវិទូ* និងអតិសុខុមវិទូ) និង ផ្ដល់ជូនមន្ទីរពេទ្យនូវការវិភាគកាន់តែលម្អិតដូចជាការធ្វើតេស្តគីមីជីវសាស្ត្រ តេស្តប្រព័ន្ធភាពស៊ាំ ចាំបាច់សម្រាប់ការសុំពិនិត្យពិសេសៗ និង សម្រាប់ការអង្កេតស្រាវជ្រាវ ។ ក្នុងទសវត្សទី ៦០ មន្ទីរពិសោធន៍គីមីទាំងនេះបានធ្វើការស្រាវជ្រាវលើជាតិអាផ្លាតុកស៊ីន ឬលើជំងឺអេម៉ូគ្លោប៊ីន និង លើអង់ស៊ីម Glucose-6-Phosphate Déshydrogénase ។

មន្ទីរពិសោធន៍ជាលិកាមួយ បង្កើតដោយវេជ្ជបណ្ឌិត *Jean-Jacques Salaun* បានឆ្លើយតប ទៅនឹងតម្រូវការរបស់ក្រុមវេជ្ជបណ្ឌិត និងបានចូលរួមក្នុងការសិក្សាពិសោធន៍លើសត្វផ្នែកវីរុសសាស្ត្រ។ លោកបានរកឃើញ វីរុសសត្វប្រចៀវភ្នំពេញ ក្នុងឆ្នាំ ១៩៦៩ ។ នៅពេលនោះ ចំនួនបុគ្គលិកបានកើនឡើងដល់ ១៤២ នាក់។ ការគាំទ្រប្រកបដោយប្រសិទ្ធភាពពីអង្គភាពជាតិខ្មែរនានា រួមជាមួយ ការជ្រោមជ្រែងពីបារាំង បានអនុញ្ញាតអោយសម្រេចបានជោគជ័យដ៏ត្រចះត្រចង់នេះ និងជាគំរូមួយ នៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា រវាងប្រទេសទាំងពីរក្នុងវិស័យវិទ្យាសាស្ត្រ ។


Source : “Institut Pasteur / Musée Pasteur”

*ការរៀបចំរបាយថ្នាលបណ្ដុះបាក់តេរី (១៩៦០)*

*វេជ្ជបណ្ឌិត Yves Goueffon* ក៏ដូចជាអតីតប្រធានវិទ្យាស្ថានមុនលោក មានកិច្ចការចម្បងបំផុតគឺគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តការសាងសង់ វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញថ្មី នៅទីតាំងជ្រោយចង្វារ។ គឺជាអគារដ៏ស្អាត មានប្រវែងបណ្ដោយ ៩០ ម៉ែត្រ កម្ពស់ពីរជាន់ និងមានជាន់ផ្ទាល់ដី ។ អគារនេះមានមន្ទីរពិសោធន៍នានាលើ ៣/៤ នៃផ្ទៃអគារ និងមានផ្នែករដ្ឋបាល។ ជាន់ផ្ទាល់ដីមានមេបណ្ដាញម៉ាស៊ីនត្រជាក់និងឃ្លាំង ឯជាន់ទី ១ ប្រើសម្រាប់មន្ទីរពិសោធន៍ជីវវិទ្យា ចំណែកជាន់ពី ២ ប្រើសម្រាប់ការផលិតថ្នាំបង្ការ។ គម្រោងនេះ ជាលទ្ធផលនៃកិច្ចសន្យានៅឆ្នាំ១៩៥៦ រវាងរដ្ឋាភិបាលកម្ពុជា (មិនមែនរវាងវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ) ជាមួយផ្នែកជំនួយសេដ្ឋកិច្ចបារាំង។ បន្ទាប់ពីឆ្លងកាត់បញ្ហាលំបាកជាច្រើនរាប់មិនអស់ អគារដ៏ប្រណិតនេះ ដែលបានរចនាឡើងដោយស្ថាបត្យករដ៏ល្បីល្បាញ គឺលោក **វណ្ណ ម៉ូលីវណ្ណ** ហើយដែលបច្ចុប្បន្ន យើងនៅតែអាចឃើញលើទីតាំងអតីតវិទ្យាស្ថាននៅឯជ្រោយចង្វារនោះ បានលេចចេញពីដីជារូបរាងឡើងម្តងបន្តិចៗ ក៏ប៉ុន្តែអគារនោះមិនដែលបានដំណើរការនោះទេ។ ព្រឹត្តិការណ៍នានានៅឆ្នាំ១៩៧៥ បាននាំមកដល់អគារនោះនូវការសំពងមរណៈមួយ តាំងពីមុនពេលដែលវិទ្យាស្ថាននេះ ទទួលបានឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់ទៅទៀត ។

# ឆ្នាំ១៩៧៥-១៩៧៩ ៖ ពេលវេលាខ្មៅងងឹត

*ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឆ្នាំមានសង្គ្រាមនៅកម្ពុជាបានប៉ះទង្គិចវិទ្យាស្ថានយ៉ាងធ្ងន់ធ្ងរ ។ បុគ្គលិកទាំងអស់បានបាត់ខ្លួន ហើយអគារមួយផ្នែកធំត្រូវបានបំផ្លាញ ។*

ក្នុងអំឡុងពេលនេះ ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលធ្លាក់ដុនដាបទាំងស្រុងនៃផ្នែកសុខាភិបាល ពោលគឺ មិនមានការចាក់វ៉ាក់សាំង អវត្តមានទាំងស្រុងនៃការធ្វើរោគវិនិច្ឆ័យជីវសាស្ត្រ និងការថែទាំវេជ្ជសាស្ត្រ។ សភាពទន់ខ្សោយបំផុតផ្នែករាង្គកាយរបស់ប្រជាជននៅឆ្នាំ១៩៧៩ បន្ថែមលើកង្វះប្រព័ន្ធអនាម័យសាធារណៈត្រឹមត្រូវ បានបង្កើតជាស្ថានភាពអេពីដេមីសាស្ត្រមួយធ្ងន់ធ្ងរបំផុត។ រោគវិនិច្ឆ័យនៃជំងឺឆ្លង គឺអាចធ្វើបានតែតាមរយៈរោគសញ្ញាគ្លីនិក ដោយសារភាពខ្វះខាត សឹងតែគ្មានមធ្យោបាយធ្វើរោគវិនិច្ឆ័យជីវសាស្ត្រ រួមជាមួយអវត្តមានបុគ្គលិកវិទ្យាសាស្ត្រដែលបានបាត់ខ្លួនផង។ ជំងឺគ្រុនចាញ់ និងជំងឺរបេង គឺជាបញ្ហាប្រឈមធ្ងន់ធ្ងរបំផុត យ៉ាងណាមិញ ដោយមានជំនួយពីអង្គការយូនីសេហ្វ កម្មវិធីសុខាភិបាលពិសេសនានា សម្រាប់ជំងឺទាំងពីរនេះត្រូវបានដាក់ឱ្យដំណើរការ។ ប៉ុន្តែកម្ពុជាក៏បានជួបប្រទះគ្រោះជំងឺរាតត្បាតផ្សេងៗ ដូចជាជំងឺអាសន្នរោគ និង ជំងឺរាគមួលជាដើម ដែលជាញឹកញាប់កើតឡើងលើ អ្នកត្រូវគេជម្លៀសផ្លាស់ប្តូរទីតាំង ជនភៀសខ្លួន ឬ អ្នកទោស ។ ករណីជំងឺប៉េស្ត ជំងឺអង់ត្រាក់ ជំងឺឆ្កែឆ្កួត ជំងឺតេតាណូស ក៏ត្រូវបានរាយការណ៍ថាកើតមានផងដែរ រីឯជំងឺគ្រុនពងបែក ក៏បានបង្កជាបញ្ហាយ៉ាងធ្ងន់ធ្ងរនៅតាមកសិដ្ឋាន។ ជំងឺឃ្លង់នៅបន្តជាករណីពិសេសមួយ ទោះបី ជាការអកុសលមានការសម្លាប់បំបាត់អ្នកជំងឺឃ្លង់ជាប្រព័ន្ធនៅក្នុងរបបងងឹត ឆ្នាំ ១៩៧៦-១៩៧៧ ក៏ដោយ ។

អតីតវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា លែងមានមន្ទីរពិសោធន៍ជីវគីមីសាស្ត្រ និងវីរុសសាស្ត្រទៀតហើយ ដោយមន្ទីរពិសោធន៍ទាំងនេះក៏ដូចជាកន្លែងរក្សាសត្វពិសោធន៍ ត្រូវបានបំផ្លាញទាំងស្រុង។ ផ្នែកមន្ទីរពិសោធន៍បាក់តេរីនៅឃើញជាអគារនៅឡើយ ប៉ុន្តែបានខូចខាតយ៉ាងធ្ងន់ធ្ងរ។ អគារបីជាន់នេះ បានសាងសង់តាំងពីចុងទសវត្សរ៍ឆ្នាំ ៥០ ដែលនៅមិនទាន់បានសម្ពោធបើកដំណើរការ នៅមានរូបរាងទាំងមូល ប៉ុន្តែប្រព័ន្ធទឹកស្អាត និងប្រព័ន្ធខ្សែរអគ្គិសនីបានខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយកញ្ចក់ទ្វារបង្អួចទាំងអស់បានបែកគ្មានសល់។ សម្ភារៈវិទ្យាសាស្ត្រទាំងប៉ុន្មានបានបាត់អស់។ ទីតាំងនេះត្រូវបានក្រុមគ្រួសារកម្មកររោងចក្រប៊ីចេង និងរោងអារឈើ នៅក្បែរនោះ ចូលកាន់កាប់ជាកន្លែងស្នាក់នៅ។ សភាពបែបនេះនៅតែបន្តហើយប្រហែលជាដុនដាបជាងនេះទៅទៀតនៅឆ្នាំ ១៩៨៣ នៅពេលដែល *សាស្ត្រាចារ្យ Durosoir* និង *បណ្ឌិត គ្រុយ ស៊ុនឡាយ* បានចុះទៅពិនិត្យមើល ។

**ចាប់ពីឆ្នាំ ១៩៧៩ ក្រសួងសុខាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ចិញ្ចឹមក្តីសង្ឃឹម ក្នុងការកសាងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាឡើងវិញ។**



ទិដ្ឋភាពទូទៅនៃវិទ្យាស្ថាន
ប៉ាស្ទ័រទី២ នៅទួលគោក
(១៩៨៦)

# ឆ្នាំ១៩៨៦-១៩៩៤
# វិទ្យាស្ថានប៉ាស្ទ័រ ទួលគោក



# ឆ្ពោះទៅរកការរស់រានឡើងវិញជាលើកដំបូង

*នៅឆ្នាំ ១៩៨១ តាមរយៈវិទ្យាស្ថានជាតិសុខភាពសាធារណៈ និងអេពីដេមីសាស្ត្រ (INSPE) នៅទីក្រុងហាណូយ ទំនាក់ទំនងត្រូវបានភ្ជាប់រវាងអ្នកវិទ្យាសាស្ត្រនៃវិទ្យាស្ថានប៉ាស្ទ័រក្រុងប៉ារីស និង ប្រជាជនកម្ពុជា។ ការងារបន្ទាន់ទីមួយ ក្នុងឆ្នាំ ១៩៨១ គឺបង្កើតគម្រោងរៀបចំបណ្តាញអេពីដេមីសាស្ត្រ និងអនាម័យសាធារណៈ ដោយផ្តោតជាបន្ទាន់លើការបណ្តុះបណ្តាលបុគ្គលិកវិទ្យាសាស្ត្រក្នុងផ្នែកនេះ។*

នៅខែឧសភា ឆ្នាំ ១៩៨១ ការដាក់អោយដំណើរការឡើងវិញនៃវិទ្យាស្ថានប៉ាស្ទ័រនៅភ្នំពេញ ត្រូវបានចាត់ទុកជាអាទិភាពដោយសមាជនៃរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ប៉ុន្តែភ្លាមនោះគេយល់ថាមិនសមហេតុផលទេក្នុងការស្តារឡើងវិញវិទ្យាស្ថានប៉ាស្ទ័រមួយ ដែលអាចទៅដល់បានតែតាមផ្លូវទឹក ដោយស្ពានតភ្ជាប់ពីទីក្រុងទៅត្រើយម្ខាងជ្រោយចង្វារត្រូវបានបំផ្លាញក្នុងឆ្នាំ ១៩៧២ ។ ការស្ថិតនៅដាច់ឆ្ងាយពីគេបែបនេះ អាចធ្វើទៅបានសម្រាប់វិទ្យាស្ថានបសុវេជ្ជសាស្ត្រមួយ ប៉ុន្តែមិនអាចទេសម្រាប់វិទ្យាស្ថានមួយដែលមានបេសកម្មផ្នែកសុខភាពមនុស្ស ។

នៅខែកញ្ញា ឆ្នាំ១៩៨៥ ពេលនៅទីក្រុងប៉ារីស (ដំណើរជាឯកជន) អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា លោកវេជ្ជបណ្ឌិត នូត សារង្សបានស្នើសុំការណាត់ជួបជាមួយសាស្ត្រាចារ្យ *Jean-Luc Durosoir* ដែលជា អគ្គប្រតិភូបណ្តាញអន្តរជាតិនៃបណ្តាវិទ្យាស្ថានប៉ាស្ទ័រ ។ ក្នុងពេលសន្ទនាគ្នា លោកទាំងពីរបានពិភាក្សាអំពីដំណាក់កាលពោរពេញដោយផលិតភាព និង ដំណាក់កាលលំបាកផ្សេងៗ ដែលវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានឆ្លងកាត់ អំពីទំនាក់ទំនងជិតស្និទ្ធនាពេលកន្លងមករវាង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងមហាវិទ្យាល័យវេជ្ជសាស្ត្ររាជធានីភ្នំពេញ អំពីការបណ្តុះបណ្តាលបុគ្គលិកវិទ្យា-សាស្ត្រ និង អំពីការបង្កើតជាមន្ទីរពិសោធន៍អនាម័យជាតិ និងសុខភាពសាធារណៈមួយដោយមានជំនួយពីវិទ្យាស្ថានជាតិអនាម័យនិងអេពីដេមីសាស្ត្រនៅហាណូយ និង ជំនួយពីអង្គការក្រៅរដ្ឋាភិបាលនានា។ គំនិតផ្តួចផ្តើមនេះបន្តផ្លូវទៅមុខបាន ល្ពឹកណាជំនួយផ្លូវការពីវិទ្យា-ស្ថានប៉ាស្ទ័រប៉ារីស អាចចេញជារូបរាងឡើង។

ការគ្រោងបេសកកម្មស្វែងយល់មួយរបស់អ្នកវិទ្យាស្ថានប៉ាស្ទ័រប៉ារីសមកកាន់ប្រទេសកម្ពុជានៅឆ្នាំ ១៩៨៦ បានប្រាកដឡើង ដោយសារមានការអញ្ជើញអោយមកចូលរួមក្នុងការសម្ពោធផ្នែកមន្ទីរពិសោធន៍មួយ នៅក្នុងវិទ្យា-ស្ថានអនាម័យ អេពីដេមីសាស្ត្រ និងសុខភាពសាធារណៈ ដែលអង្គការយូនីសេហ្វ សម្រេចបង្កើត តាមរយៈជំនួយពីសមាគមន៍សម្រាប់ការអភិវឌ្ឍន៍ទំនាក់ទំនងជាមួយកម្ពុជា (ADRAC) មានទីតាំងនៅជាយក្រុងភ្នំពេញ ឯទួលគោក ក្នុងអតីតបន្ទាយមួយ (ការងារសាងសង់នឹងចាប់ផ្តើមនៅខែកក្កដា ដល់ខែសីហា ឆ្នាំ១៩៨៤)។

# ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៨៦ ៖ ការសម្ពោធ វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ នៅទួលគោក

ផ្នែកមន្ទីរពិសោធន៍នេះ ទទួលបានការជ្រោមជ្រែងជាច្រើន ពីអ្នកបច្ចេកទេសវិទ្យាស្ថានប៉ាស្ទ័រប៉ារីស ដែលគេបញ្ជូនមកជួយបណ្តុះបណ្តាល *(វេជ្ជបណ្ឌិត Gilles Marchal* និង *Paul Martin)* នឹងត្រូវសម្ពោធនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ ១៩៨៦ ក្រោមឈ្មោះថា វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ នៅម្តុំទួលគោក និងដាក់នៅក្រោមការដឹកនាំរបស់ *អ្នកស្រីបណ្ឌិត គ្រុយស៊ុនឡាយ*។ ពិធីសម្ពោធបានប្រារព្ធឡើងដោយមានវត្តមាន *លោកវេជ្ជបណ្ឌិត ឃិត គឹមសេង* ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល លោកសាស្ត្រាចារ្យ *Durosoir* ជាអគ្គប្រតិភូនៃបណ្តាវិទ្យាស្ថានប៉ាស្ទ័រឯនាយសមុទ្ទ និងកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និង លោក *Jérome Kanapa* ជាប្រធាន ADRAC ។



*មន្ទីរពិសោធន៍ (១៩៨៦)*

វិទ្យាស្ថានមានបុគ្គលិក ពេលនោះ ចំនួន ២៥ នាក់ ដែលចូលរួមក្នុងវិរភាពថ្មីនេះ។ អ្នកមាននាទីផ្នែកវិទ្យាសាស្ត្របានដឹកនាំបុគ្គលិកផ្នែកសេវាវិភាគជីវវេជ្ជសាស្ត្រ និងអតិសុខុមសាស្ត្រ ក៏ដូចជាការស្រាវជ្រាវលើបញ្ហាដង្កូវពោះវៀន ជំងឺគ្រុនឈាម និង មូលហេតុនៃជំងឺរាគរូសរបស់កុមារ។ វិទ្យាស្ថានប៉ាស្ទ័រក្នុងទីក្រុងភ្នំពេញ បណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន បុគ្គលិកបច្ចេកទេសរបស់រដ្ឋ នៅទីក្រុងភ្នំពេញ និងនៅតាមខេត្ត ព្រមទាំងនិស្សិត លើផ្នែកប៉ារ៉ាសិតសាស្ត្រ ផ្នែកលោហិតសាស្ត្រ ផ្នែកជីវគីមីវេជ្ជសាស្ត្រ ផ្នែកវិភាគសម្ភារៈសេនេទិក និងផ្នែកវីរុសសាស្ត្រសម្រាប់វេជ្ជសាស្ត្រ ។

ចាប់ពីឆ្នាំ ១៩៨៧ កម្មវិធីសហប្រតិបត្តិការមួយ ជាមួយវិទ្យាស្ថានប៉ាស្ទ័រនៅទីក្រុងប៉ារីស ត្រូវបានស្នើឡើង។ ជាបឋម បេសកកម្មដំបូង ក្នុងខែមីនា ដល់ខែមេសា ឆ្នាំ ១៩៨៧ នឹងពាំនាំមកនូវជំនួយសម្រាប់ការចាប់ផ្តើមដំណើរការ និង ការរៀបចំផ្នែកបច្ចេកទេសនៃមន្ទីរពិសោធន៍ លោហិតសាស្ត្រ និង ប៉ារ៉ាសិតសាស្ត្រ។ ការចាប់ផ្តើមដំណើរការនេះ អមទៅដោយការបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេសក្នុងមុខវិជ្ជាទាំងពីរនេះ។ នៅខែធ្នូ ឆ្នាំ១៩៨៧ បេសកកម្មទីពីរ ផ្តោតមួយផ្នែកលើការបង្រៀនជីវគីមីវិទ្យា ហើយមួយផ្នែកទៀត ជាការប្រតិបត្តិចាប់យកចំណេះដឹងបច្ចេកទេសដែលអាចអនុវត្តបាន ដោយបុគ្គលិកនៃវិទ្យាស្ថានប៉ាស្ទ័រក្នុងទីក្រុងភ្នំពេញ។ បេសកកម្មទីបី ផ្នែកជីវគីមីវិទ្យា បានធ្វើឡើងនៅខែធ្នូ ឆ្នាំ១៩៨៨ ។



*ផ្នែកមួយនៃបុគ្គលិកនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅទួលគោក (១៩៨៦)*

ចាប់ពីឆ្នាំ ១៩៨៨ បេសកកម្មជាច្រើនដែលរៀបចំដោយអគ្គប្រតិភូនៃវិទ្យាស្ថានប៉ាស្ទ័រឯនាយសមុទ្ទ (ក្រោយមកក្លាយជាបណ្តាញអន្តរជាតិនៃវិទ្យាស្ថានប៉ាស្ទ័រ និងវិទ្យាស្ថានពាក់ព័ន្ធ) ត្រូវបានបំពេញ (*បណ្ឌិត Bernard Ivanhoe, Georges Le Gonidec, Yves Germani* ...) ការបណ្តុះបណ្តាលត្រូវបានផ្តល់ និង ជំនួយមួយជាសម្ភារៈ និង របស់ប្រើប្រាស់ផ្សេងៗ ត្រូវបានផ្តល់នៅក្នុងឱកាសនេះ ឬ នៅពេលបន្ទាប់ពីបេសកកម្ម។

បេសកកម្មនីមួយៗ ជាឱកាសក្នុងការរៀបរៀងជាកម្មវិធី ដោយផ្អែកលើចំណេះដឹងទទួលបានកន្លងមក ប៉ុន្តែក៏តែងតែនាំមុខដោយការបញ្ជូនមកជាមុន នូវសម្ភារៈ និងផលិតផលជីវសាស្ត្រជាច្រើន ដែលចាំបាច់មិនត្រឹមតែសម្រាប់ការដំណើរការដោយរលូននៃបេសកកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការបន្តសកម្មភាពបន្ទាប់ពីបេសកកម្មទាំងនោះផងដែរ។ បេសកកម្មចុងក្រោយមួយ ផ្តោតលើបាក់តេរីសាស្ត្រ បានធ្វើឡើងក្នុងខែឧសភា-មិថុនា ឆ្នាំ ១៩៨៩។ ម្នាក់ក្នុងចំណោមអ្នកមកបេសកកម្ម បានបន្តស្នាក់នៅរហូតដល់ពាក់កណ្តាលខែកក្កដា ដើម្បីវាយតម្លៃសកម្មភាពរបស់មន្ទីរពិសោធន៍ផ្សេងៗដែលបានបង្កើតឡើង និង ដើម្បីផ្សព្វផ្សាយអំពីការពិនិត្យមន្ទីរពិសោធន៍របស់វិទ្យាស្ថាន ទៅដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាពនានាក្នុងក្រុងភ្នំពេញ ក៏ដូចជាដើម្បីមើលឃើញដំណើរការរបស់វិទ្យាស្ថាន ក្នុងល្បឿនលឿនមួយគួរអោយកត់សំគាល់។ បន្ទមក មានការចាត់អោយ “អ្នកជំនួយការបច្ចេកទេស” មួយរូបមកបំពេញការងាររយៈពេលវែង (ឱសថការីជីវវិទូ *Michel Blanchot*) ។

**នៅពេលនោះ វិទ្យាស្ថានប្រឈមជាមួយកង្វះប្រភពផ្គត់ផ្គង់ទឹកស្អាត និង ការដាច់ចរន្តអគ្គិសនី ។**



វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មានទីតាំង
នៅលើមហាវិថីព្រះមុនីវង្ស
រាជធានីភ្នំពេញ (តាំងពីឆ្នាំ ១៩៩៥)

# វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
# នៅមហាវិថីព្រះមុនីវង្ស

(ទីតាំងបច្ចុប្បន្ន)

## ការពិចារណាអំពី វិទ្យាស្ថានប៉ាស្ទ័រ នៅលើទីតាំងថ្មីមួយ

មិនយូរប៉ុន្មាន គេយល់ឃើញកាន់តែច្បាស់ថា វិទ្យាស្ថានដែលមានទីតាំងនៅទួលគោក ស្ថិតនៅឆ្ងាយពេកពីកណ្តាលទីក្រុង និងពីមន្ទីរពេទ្យនានា ដែលជាកត្តាធ្វើអោយថយយ៉ាងខ្លាំង នូវសកម្មភាពរបស់វិទ្យាស្ថានប៉ាស្ទ័រ និងអាចរារាំងដល់ការអភិវឌ្ឍន៍វិទ្យាស្ថាន នាពេលអនាគត។ គេក៏ស្វែងយល់ឃើញភ្លាមថា ទីកន្លែងតែមួយគត់ ដែលអាចទទួល ក្នុងជំហានដំបូង នូវមជ្ឈមណ្ឌលប្រមូលវត្ថុវិភាគក្នុងក្រុងបែបនេះ គឺមន្ទីពិសោធន៍នៃមន្ទីរពេទ្យកាល់ម៉ែត។ មន្ទីរពិសោធន៍នេះមានលក្ខណៈអំណោយផលដោយបែរទៅរុក្ខវិថីធំ គឺផ្លូវអាចារ្យមាន (បច្ចុប្បន្ន រុក្ខវិថីព្រះមុនីវង្ស) មានច្រកចេញចូលដាច់ដោយឡែកពីច្រកចូលធំរបស់មន្ទីរពេទ្យកាល់ម៉ែត ដែលពេលនោះគេហៅថា មន្ទីរពេទ្យបដិវត្តន៍។

កន្លែងនេះអាចធ្វើជាកន្លែងរដ្ឋបាល និងបន្ទប់យកសំណាក បានយ៉ាងសមស្រប។ ម្យ៉ាងទៀត ទីធ្លាជុំវិញមន្ទីរពិសោធន៍របស់មន្ទីរពេទ្យកាល់ម៉ែតនេះ អាចនៅសាងសង់អគារបាន ហើយទីតាំងនៅជិតមហាវិទ្យាល័យវេជ្ជសាស្ត្រ អាចអនុញ្ញាតអោយចាត់បញ្ចូលវិទ្យាស្ថានទៅក្នុងបណ្តុំមួយមាន មន្ទីរពេទ្យ និងសាកលវិទ្យាល័យ ។

បេសកកម្មបន្តបន្ទាប់ជាច្រើនត្រូវបានបំពេញនៅឯក្នុងទីក្រុងភ្នំពេញ ដឹកនាំដោយសាស្ត្រាចារ្យ *Jean-Luc Durosoir* អគ្គប្រតិភូនៃបណ្តាញអន្តរជាតិរបស់បណ្តាវិទ្យាស្ថានប៉ាស្ទ័រ។ វិទ្យាស្ថានប៉ាស្ទ័រទីក្រុងភ្នំពេញនៅទួលគោក បានដំណើរការស្របតាមកិច្ចព្រមព្រៀង ថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៥៨ រវាងប្រធានក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីកម្ពុជា និងប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានប៉ាស្ទ័រទីក្រុងប៉ារីស។ មិនយូរប៉ុន្មាន ក៏មានភាពចាំបាច់ក្នុងការរៀបចំជាកិច្ចព្រមព្រៀងថ្មីមួយ ដែលបានផ្លាស់ប្តូរ វិទ្យាស្ថានប៉ាស្ទ័រក្រុងភ្នំពេញ ទៅជាវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាវិញ ខណៈដែលរដ្ឋកម្ពុជាបានចាត់ទុកវិទ្យាស្ថានថាមានលក្ខណៈជាប្រយោជន៍សាធារណៈ មានបុគ្គលិកលក្ខណៈស៊ីវិល និងមានស្វ័យភាពហិរញ្ញវត្ថុ។ ក្នុងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស វិទ្យាស្ថានបានក្លាយជាអង្គភាពមួយនៃវិទ្យាស្ថានប៉ាស្ទ័រនៅទីក្រុងប៉ារីស។ នាយករបស់វិទ្យាស្ថាន ត្រូវតែងតាំងដោយនាយកវិទ្យាស្ថានប៉ាស្ទ័រនៅទីក្រុងប៉ារីស ដោយមានការយល់ព្រមពីរដ្ឋកម្ពុជា ។

## ១៩៩២ ៖ ការចុះហត្ថលេខាលើអនុសញ្ញា

ក្រោមការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់ ប្រកបដោយឆន្ទៈ របស់បណ្ឌិត គ្រុយ ស៊ុនឡាយ ដើម្បីការលេចរូបឡើងជាថ្មីទៀត របស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងការមកកាន់តំណែងបន្តរបស់សាស្ត្រាចារ្យ *Michel Blanchot* គំនិតផ្តួចផ្តើមក៏បន្តដំណើរទៅមុខទៀត។ ជំនួបនានារវាងលោកវេជ្ជបណ្ឌិត *Durosoir* ជាមួយលោកវេជ្ជបណ្ឌិត យឹម ឆៃលី ជារដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា ជាមួយអនុរដ្ឋមន្ត្រី លោក *ឈា ថាំង* ជាមួយអគ្គនាយកសុខាភិបាល លោក *វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង* និង រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា លោក ហោ ណាំហុង ត្រូវបានរៀបចំឡើងនាចុងខែកក្កដា ឆ្នាំ ១៩៩២ ។

ទីបំផុត ផ្ទៃដីមួយសម្រាប់ការសាងសង់វិទ្យាស្ថានប៉ាស្ទ័រថ្មី នៅជិតមន្ទីរពេទ្យកាល់ម៉ែត ត្រូវបានកំណត់ និងបែងចែកអោយ។ គម្រោងអនុសញ្ញារវាងរដ្ឋកម្ពុជា និងវិទ្យាស្ថានប៉ាស្ទ័រ ដែលរៀបចំព្រៀងនៅទីក្រុងប៉ារីស ត្រូវបានពិភាក្សា និងឈានដល់កិច្ចព្រមព្រៀងមួយលើចំណុចនានានៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩២។ អត្ថបទអនុសញ្ញាត្រូវបានដាក់ជូនក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ។

នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៩២ កិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខានៅទីក្រុងភ្នំពេញ ដោយ សាស្ត្រាចារ្យ *Maxime Schwartz* អគ្គនាយកវិទ្យាស្ថានប៉ាស្ទ័រ និង*លោកវេជ្ជបណ្ឌិត យឹម ឆៃលី* ជាតំណាងអោយភាគីរដ្ឋកម្ពុជា ។

## ១៩៩៤ ៖ ពិធីបញ្ចុះបឋមសិលា

បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀង កាលវិភាគនៃការសាងសង់ត្រូវបានលម្អិត រួមជាមួយនិងការតែងតាំងមនុស្សពីរនាក់ដើម្បីអនុវត្តការកសាងនេះឡើងវិញ គឺ លោក *Christian Quintin* ជាភ្នាក់ងាររដ្ឋបាល និង វេជ្ជបណ្ឌិត *Flye Sainte Marie* ជាអនាគតនាយកនៃវិទ្យាស្ថាន ។ អ្នកទាំងពីរនាក់នេះ មានតួនាទីយ៉ាងសំខាន់ សហការជាមួយលោកស្រី *គ្រុយ ស៊ុនឡាយ* ក្នុងការពិនិត្យតាមដានការដ្ឋានសំណង់ រហូតដល់ពេលនៃការសម្ពោធ ។

ថ្ងៃទី ២៩ ខែមីនា ឆ្នាំ១៩៩៤ ពិធីបញ្ចុះបឋមសិលា ត្រូវបានប្រារព្ធឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលបារាំង លោកស្រី *Simone Veil* និង *វេជ្ជបណ្ឌិត ឈា ថាំង* ជារដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា ដោយមានវត្តមានលោកសាស្ត្រាចារ្យ *Maxime Schwartz* អគ្គនាយកវិទ្យាស្ថានប៉ាស្ទ័រ។ ក្នុងអំឡុងពេលស្នាក់នៅនេះ គណៈប្រតិភូបារាំង បានជួបកាលវិភាគការងារសាងសង់ វិទ្យាស្ថានប៉ាស្ទ័រថ្មី នៅកម្ពុជា ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធរបស់កិច្ចព្រមព្រៀង។ ទីដីទំហំ ៧ ៨៣៦ ម៉ែត្រការ៉េ ត្រូវបានជួលអោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា សម្រាប់រយៈពេលនៃកិច្ចព្រមព្រៀងនេះ ក្នុងតម្លៃជួលប្រចាំឆ្នាំ ចំនួនមួយរៀល ជានិមិត្តរូប។ ទីដីនៅជ្រោយចង្វារត្រូវបានប្រគល់អោយទៅក្រសួងសុខាភិបាលកម្ពុជាវិញ។ លោក *Bernard Darras* ជាស្ថាបត្យករដែលបានរចនាវិទ្យាស្ថានប៉ាស្ទ័រមួយចំនួន ជាពិសេសនៅទ្វីបអាហ្វ្រិក បានត្រូវគេអញ្ជើញឱ្យចូលរួមអនុវត្តគម្រោងនេះ។



*ពិធីបញ្ចុះបឋមសិលាដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលបារាំង Simone Veil និង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា លោក ឈា ថាំង (ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ១៩៩៤)*

ជាមួយបុគ្គលជាច្រើនដូចជា *វេជ្ជបណ្ឌិត ឌី ណារ៉ុងរិទ្ធ* និង *វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង* ជារដ្ឋលេខាធិការ វេជ្ជបណ្ឌិត អេង ហួត ជាប្រធានកម្មវិធីគាំពារមាតានិងទារក *វេជ្ជបណ្ឌិត អ៊ុំ សុផល* ជានាយកវិទ្យាស្ថានអនាម័យ *វេជ្ជបណ្ឌិត គង់ គឹមសាន* មកពីវិទ្យាស្ថានប្រយុទ្ធនិងជំងឺរបេង *វេជ្ជបណ្ឌិត ខុន នំហេង* មកពីផ្នែកជំងឺឃ្លង់ លោក *សេង លឹមណើយ* ជា

អនុរដ្ឋមន្ត្រី។ គាត់ទាំងអស់គ្នាស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការវិលត្រឡប់មកវិញរបស់វិទ្យាស្ថានប៉ាស្ទ័រក្នុងប្រទេសកម្ពុជា និង ធានាចំពោះថ្នាក់ដឹកនាំវិទ្យាស្ថាន ថានឹងផ្ដល់ការជួយជ្រោមជ្រែងរបស់គាត់នាពេលអនាគត។ លោក *François Fillon* ពេលនោះជារដ្ឋមន្ត្រីក្រសួងអប់រំ និងស្រាវជ្រាវ ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា មានអារម្មណ៍ភ្ញាក់ផ្អើលជាខ្លាំងពេលឃើញវិសាលភាពនៃការដ្ឋានសាងសង់ ។

**ការផ្ទេរសកម្មភាពរបស់វិទ្យាស្ថានពីទួលគោកមកវិទ្យាស្ថានបច្ចុប្បន្ន គ្រោងធ្វើនៅខែវិច្ឆិកា-ធ្នូ ឆ្នាំ១៩៩៤ ។**

## ១៩៩៥ ៖ ការសម្ពោធ

**ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៩៥** គឺរយៈពេល ១០០ ឆ្នាំ បន្ទាប់ពីមរណៈភាពរបស់ លោក *Louis Pasteur* វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាត្រូវបានសម្ពោធជាផ្លូវការដោយ ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ សហនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានលោកសាស្ត្រាចារ្យ *Bernard Debré* រដ្ឋមន្ត្រីកិច្ចសហប្រតិបត្តិការបារាំង។ លោកបណ្ឌិត *François Flye-Sainte Marie* ចូលកាន់តំណែងជាផ្លូវការជានាយកវិទ្យាស្ថាន ហើយ *អ្នកស្រីបណ្ឌិត គ្រុយ ស៊ុនឡាយ* ដែលជាស្ថាបនិកម្នាក់នៃការករកើតឡើងវិញរបស់នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ត្រូវបានតែងតាំងជានាយករង ។



*ការចាក់ថ្នាំនៅសើស្បែក បង្ការជំងឺឆ្កែឆ្កួត*

**សករាជថ្មីមួយ បើកទំព័រសម្រាប់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងសម្រាប់កិច្ចសហប្រតិបត្តិការបារាំង-ខ្មែរ ។**

វិទ្យាស្ថានថ្មី បានបើកទ្វារជូនសាធារណៈជន នៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៥ ។ បុគ្គលិករួមមានចំនួន ៥៩ នាក់ ធ្វើការនៅតាមផ្នែកវីរុសសាស្ត្រ ផ្នែកអេពីដេមីសាស្ត្រ និងសុខភាពសាធារណៈ ដែលក្នុងនោះមានសេវាចាក់ថ្នាំបង្ការ ការបង្ការជំងឺឆ្កែឆ្កួត និងមជ្ឈមណ្ឌលធ្វើតេស្តមេរោគហ៊ីវ ។ នៅឆ្នាំ១៩៩៦ មួយភាគធំនៃសកម្មភាពការងាររបស់វិទ្យាស្ថាន ផ្ដោតទៅលើការឆ្លងវីរុសហ៊ីវ។ អាទិភាពគោលមួយនេះនៅក្នុងចំណោមទាំងអស់ បានចូលមកដាក់កំហិតដោយសារស្ថានភាពគួរឱ្យព្រួយបារម្ភនៃការឆ្លងរាលដាលមេរោគហ៊ីវ និង ជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងរបាយការណ៍ដំបូងអំពីការងាររបស់អង្គភាពថ្មីនេះ (ឆ្នាំ ១៩៩៦) នាយកវិទ្យាស្ថានលោកវេជ្ជបណ្ឌិត *François Flye Sainte Marie* សន្និដ្ឋានថា ៖ “បញ្ហាប្រឈមមានច្រើនសម្រាប់វិទ្យាស្ថានដ៏ក្មេងខ្ចីនេះ ហើយបេសកកម្មរបស់វិទ្យាស្ថាន ត្រូវតែបន្តរៀបចំនៅក្នុងការងារបន្ទាន់ក៏ដូចជានៅក្នុងផែនការរយៈពេលវែង” ។



*មន្ទីរពិសោធន៍បរិស្ថាន និងសុវត្ថិភាពចំណីអាហារ*

អ្នកបន្តវេនពីគាត់ គឺសាស្ត្រាចារ្យ *Yves BUISSON* បានបង្កើតវគ្គបណ្តុះបណ្តាលជាច្រើន (ឆ្នាំ១៩៩៩-២០០១) ដោយសារមានការបង្រៀននៅក្នុងប្រទេស និងនៅឯបរទេស ជាពិសេសអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិក និងដាក់បញ្ចូលអ្នកវិទ្យាសាស្ត្រចំនួន ៩ នាក់ ទៅក្នុងគណៈអ្នកវិទ្យាសាស្ត្រនៃបណ្តាញអន្តរជាតិ។ នៅឆ្នាំ ២០០១ ផ្នែកអេពីដេមីសាស្ត្រ វិភាគសេនេទិកមេរោគគ្រុនចាញ់ត្រូវបានបង្កើតឡើង ដែលអនុញ្ញាតឱ្យវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា សហការយ៉ាងសកម្ម ក្នុងការងារលើជំងឺគ្រុនចាញ់នៅកម្ពុជា ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និង ជាមួយអង្គការសុខភាពពិភពលោក ជាពិសេសក្នុងការតាមដានភាពស៊ាំថ្នាំរបស់មេរោគគ្រុនចាញ់ ។

នៅឆ្នាំ ២០០៣ មន្ទីរពិសោធន៍អតិសុខុមសាស្ត្រអាហារ និង វិភាគទឹក ដែលមានវត្តមានតាំងពីឆ្នាំ ១៩៩៥ មក ប៉ុន្តែជាផ្នែកមួយនៃមន្ទីរពិសោធន៍ជីវវិទ្យាវេជ្ជសាស្ត្រ បានក្លាយជាមន្ទីរពិសោធន៍ពេញលេញស្វ័យភាព។ មន្ទីរពិសោធន៍នេះ ដឹកនាំដោយ *បណ្ឌិត គ្រុយ ស៊ុនឡាយ* ក្រោយមកបានក្លាយជាមន្ទីរពិសោធន៍បរិស្ថាន និងសុវត្ថិភាពចំណីអាហារ ដែលយើងស្គាល់រហូតសព្វថ្ងៃនេះ ។

***ការស្រាវជ្រាវលើជំងឺអេដស៍បានអភិវឌ្ឍក្នុងឆ្នាំ ២០០១ ជាមួយនឹងការបង្កើតទីតាំង ANRS តំបន់អាស៊ីអាគ្នេយ៍ ដែលពឹងផ្អែកលើវិទ្យាស្ថានប៉ាស្ទ័រទីក្រុងហូជីមិញ នៅប្រទេសវៀតណាម និង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ។***

ក្នុងបរិបទនេះ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានចូលរួមក្នុងការសិក្សាស្រាវជ្រាវគ្លីនិកដំបូងៗគេ ក្នុងប្រទេសកម្ពុជា លើការការពារការឆ្លងពីម្តាយទៅកូន និង លើការធ្វើឱ្យប្រសើរឡើងនៃការព្យាបាលជំងឺសួតទាក់ទងជាមួយវីរុសហ៊ីវ-ជំងឺអេដស៍។ ការសិក្សាក៏បានពិនិត្យមើលកត្តាហានិភ័យ និងភាពធន់ទៅនឹងការឆ្លងមេរោគបែបធម្មជាតិ ផងដែរ។ នៅឆ្នាំ ២០០៦ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានពង្រីកសមត្ថភាពរបស់ខ្លួនក្នុងវិស័យស្រាវជ្រាវគ្លីនិកតាមរយៈគម្រោងសាកល្បងមួយ គឺគម្រោង “CAMELIA” ដឹកនាំដោយ ANRS និង NIH នៅលើអ្នកជំងឺដែលមានជំងឺរបេងផង និងជំងឺអេដស៍ផង។ គម្រោងទាំងនេះបាននាំទៅដល់ការបង្កើតជាក្រុមស្រាវជ្រាវគ្លីនិក “Recherche clinique” នៅក្នុងផ្នែកអេពីដេមីសាស្ត្រ និងសុខភាពសាធារណៈ ។

តាំងពីឆ្នាំ ២០០៣ មក វិទ្យាស្ថានមានសមត្ថភាពឆ្លើយតបទៅតម្រូវការរបស់អាជ្ញាធរជាតិ ដើម្បីប្រឈមមុខជាមួយបញ្ហាឆ្លងរាលដាលនៃជំងឺសាស (SARS) នៅតំបន់អាស៊ី និងបន្ទាប់មក ជាមួយការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សី H5N1។ ដោយសារតែមានក្រុមការងារនៃផ្នែកអេពីដេមីសាស្ត្រ និងសមត្ថភាពឆ្លើយតបរបស់ផ្នែកវីរុសសាស្ត្រ ក្នុងការធ្វើរោគវិនិច្ឆ័យជីវសាស្ត្រអាចជឿទុកចិត្តបានដោយរិភាគសម្ភារៈសេនេទិក វិទ្យាស្ថានបានទទួលភាពសមស្រប តាមរយៈសមត្ថភាពជំនាញរបស់ខ្លួន (មជ្ឈមណ្ឌលពិសោធន៍បង្អែកសម្រាប់មេរោគគ្រុនផ្តាសាយ មេរោគផ្លូវដង្ហើមជាដើម) ទទួលស្គាល់ដោយអាជ្ញាធរជាតិ និងអង្គការអន្តរជាតិ (WHO, FAO, ...) ។

បន្ទាប់ពីមានរលកនៃការលេចឡើងរបស់មេរោគបង្ករោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ (SARS) និងជំងឺគ្រុនផ្តាសាយបក្សី H5N1 ក្រោមការដឹកនាំរបស់លោកវេជ្ជបណ្ឌិត Jean-Louis Sarthou មន្ទីរពិសោធន៍ថ្នាក់តំបន់ ជីវសុវត្ថិភាពកម្រិតទីបី ឬ P3 ត្រូវបានសាងសង់ឡើង និងបំពាក់សម្ភារៈ ដោយប្រើជំនួយពីរដ្ឋាភិបាលប្រទេសបារាំង និង សហរដ្ឋអាមេរិក រួមជាមួយប្រាក់កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។ មន្ទីរពិសោធន៍នេះត្រូវបានសម្ពោធនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ ក្រោមអធិបតីភាពរបស់*វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង* ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល និង លោកស្រី *Rama Yadé* រដ្ឋលេខាធិការបារាំងទទួលបន្ទុកក្រសួងការបរទេស និងសិទ្ធិមនុស្ស ។

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ ជាថ្ងៃនៃពិធីប្រារព្ធខួប ៦០ ឆ្នាំ នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ហើយក្នុងឱកាសនោះ មានពិធីបញ្ចុះបឋមសិលាសាងសង់អគារមួយ ដែលមានតួនាទីថ្នាក់តំបន់សម្រាប់ការស្រាវជ្រាវពហុជំនាញ លើជំងឺឆ្លង និងលើមេរោគដែលកំពុងលេចធ្លោ (PR-ASIE) ។ ពេលនោះ វិទ្យាស្ថានស្ថិតក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ *Vincent Deubel* ។





*មន្ទីរពិសោធន៍ជីវសុវត្ថិភាពកម្រិត ៣*



**Toxorynchites** ឬ មូសដំរី ទំហំរហូតដល់ ២ សម



ការញែកប្រភេទមូសដោយប្រើស្តេរ៉េអូមីក្រូទស្សន៍



ការរក្សាទុកសំណាកសត្វមូស

ការសាងសង់នេះទ្រទង់ថវិការដោយ វិទ្យាស្ថានប៉ាស្ទ័រប៉ារីស INSERM ANRS AIRD/IRD និង មូលនិធិ Mérieux ។ ក្រោយមក អគារនេះបានសម្ពោធដោយ *ឯកឧត្តម ម៉ម ប៊ុនហេង* ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល *សាស្ត្រាចារ្យ Alice Dautry* ជាអគ្គនាយកវិទ្យាស្ថានប៉ាស្ទ័រប៉ារីស និង លោក *Serge Mostura* ជាឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា ។

**គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៣ មានបុគ្គលិក ១៦៦ នាក់ បំពេញការងារនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រួមទាំងបុគ្គលិកខ្មែរ ផ្នែករដ្ឋបាល វិទ្យាសាស្ត្រ និងបច្ចេកទេស ជាង ១៤០ នាក់ផង ។**

ប្រភេទមន្ទីរពិសោធន៍ផ្សេងៗបន្តកើតឡើងថែមទៀត ។ ក្រោមអាណត្តិរបស់វេជ្ជបណ្ឌិត *Didier Fontenille* ផ្នែកប្រព័ន្ធភាពសាំ (បណ្ឌិត *Tineke CANTAERT*) និង ផ្នែកបាណកសាស្ត្រសម្រាប់វេជ្ជសាស្ត្រ និងបសុវេជ្ជសាស្ត្រ (បណ្ឌិត *Sébastien BOYER*) ត្រូវបានបង្កើតឡើងជាផ្លូវការ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១៨ ។ អង្គភាពទាំងនេះ បានវិវត្តខ្លួនចេញពីក្រុមការងារបច្ចេកទេសដែលធ្វើការលើប្រធានបទទាំងនេះ ហើយសម្រេចបានជោគជ័យវិទ្យាសាស្ត្រ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ។

***នៅខែកក្កដា ឆ្នាំ២០១៨ និង ខែមីនា ឆ្នាំ២០១៩ មជ្ឈមណ្ឌលបង្ការជំងឺឆ្កែឆ្កួត ចំនួនពីរ នៅក្រៅក្រុងភ្នំពេញ ក៏ត្រូវបានបង្កើតឡើង នៅខេត្តបាត់ដំបង និង នៅខេត្តកំពង់ចាម ដែលអនុញ្ញាតអោយ ការទទួលថ្នាំបង្ការកាន់តែមានភាពងាយស្រួលសម្រាប់ប្រជាជនដែលប្រឈមនិងជំងឺឆ្កែឆ្កួត ។***

នៅឆ្នាំ២០២០ និងឆ្នាំ២០២១ វិទ្យាស្ថានបានពាំនាំនូវការចូលរួមយ៉ាងសំខាន់ ដល់ការឆ្លើយតបផ្នែកសុខភាពសាធារណៈ ប្រឆាំងការរាតត្បាតនៃជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា និងអនុតំបន់ទន្លេមេគង្គ។ វិទ្យាស្ថានជាមន្ទីរពិសោធន៍តែមួយគត់ ដែលអាចធ្វើតេស្ត RT-PCR រកមេរោគកូវីដ-១៩ ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២០ (អនុវត្តនៅក្នុងផ្នែកវីរុសសាស្ត្រ) រហូតដល់ពេលដែលមន្ទីរពិសោធន៍ជាតិសុខភាពសាធារណៈ (NPHL) នៃវិទ្យាស្ថានជាតិសម្រាប់សុខភាពសាធារណៈ (NIPH) អាចធ្វើតេស្តបាន។ ក្នុងអំឡុងឆ្នាំ២០២០ ស្ថាប័នទាំងពីរនេះ បានធ្វើតេស្តRT-PCRទាំងអស់សម្រាប់ជំងឺកូវីដ-១៩នៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០២១ មានមន្ទីរពិសោធន៍មួយចំនួនទៀត បានចូលរួមធ្វើកិច្ចការនេះបន្ថែមលើ NIPH និង IPC ដើម្បីពង្រីកសមត្ថភាពមន្ទីរពិសោធន៍នៅទូទាំងផ្ទៃប្រទេស។ អ្នកវិទ្យាសាស្ត្ររបស់វិទ្យាស្ថាន រួមទាំងវេជ្ជបណ្ឌិត *Laurence Baril* ជានាយកស្ត្រីទីមួយនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ក៏បានចូលរួមយ៉ាងច្រើនក្នុងនាមជាអ្នកជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍សុខភាពផ្សេងៗ។ នៅខែមេសា ឆ្នាំ២០២០ អង្គការសុខភាពពិភពលោក WHO តែងតាំងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ជាមជ្ឈមណ្ឌលបង្អែកថ្នាក់តំបន់សម្រាប់វិភាគវីរុសកូវីដ-១៩ ពោលគឺ ជាមន្ទីរពិសោធន៍មួយ ក្នុងចំណោមមន្ទីរពិសោធន៍បង្អែកទាំង ២២ នៅលើពិភពលោក ។



*ការយកសំណាកសម្រាប់រោគវិនិច្ឆ័យជំងឺ កូវីដ-១៩*

## នៅក្នុងឆ្នាំ២០២៣ គឺនៅ ៧០ ឆ្នាំ បន្ទាប់ពីការបង្កើតវិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា វិទ្យាស្ថានឈរយ៉ាងរឹងមាំនៅក្នុងប្រទេស ។

វិទ្យាស្ថាននេះត្រូវដឹកនាំដោយនាយកមួយរូប ហើយការបំពេញមុខងាររបស់គាត់ ត្រូវពិនិត្យដោយក្រុមប្រឹក្សាទំនាក់ទំនង ដែលមានសមាជិកចំនួន ១០ រូប រួមទាំងអគ្គនាយកនៃវិទ្យាស្ថានប៉ាស្ទ័រប៉ារីស។ ក្រុមប្រឹក្សានេះ មានរដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា ជាប្រធាន។ ក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ គាំទ្រថ្នាក់ដឹកនាំវិទ្យាស្ថានក្នុងការកំណត់យុទ្ធសាស្ត្រផ្នែកវិទ្យា-សាស្ត្រ ។ សមាជិករបស់ក្រុមប្រឹក្សានេះត្រូវតែងតាំងដោយ វិទ្យាស្ថានប៉ាស្ទ័រប៉ារីស និងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានពីររូបជាបុគ្គលិកអន្តរជាតិ។

វិទ្យាស្ថានមានថ្នាក់ដឹកនាំចំនួន ៣ រូប គឺ នាយក នាយករង និង នាយករដ្ឋបាលនិងហិរញ្ញវត្ថុ មានផ្នែកគាំទ្រ (រដ្ឋបាល ហិរញ្ញវត្ថុ និង ភស្តុភា) មានផ្នែកស្រាវជ្រាវចំនួនប្រាំ គឺ ផ្នែកជំងឺគ្រុនចាញ់ ផ្នែកអេពីដេមីសាស្ត្រនិងសុខភាពសាធារណៈ ផ្នែកប្រព័ន្ធភាពស៊ាំ ផ្នែកបាណកសាស្ត្រសម្រាប់វេជ្ជសាស្ត្រ និងបសុវេជ្ជសាស្ត្រ និង ផ្នែកវីរុសសាស្ត្រ។ វិទ្យាស្ថានក៏មានសេវាកម្មក្នុងវិស័យសុខភាព ដូចជា មន្ទីរពិសោធន៍ជីវវិទ្យាវេជ្ជសាស្ត្រ មន្ទីរពិសោធន៍បរិស្ថាននិងសុវត្ថិភាពចំណីអាហារ ផ្នែកចាក់ថ្នាំបង្ការ ដែលមានមជ្ឈមណ្ឌលអន្តរជាតិចាក់ថ្នាំបង្ការ និង មជ្ឈមណ្ឌលបង្ការជំងឺឆ្កែឆ្កួតនៅបីទីតាំង។ សកម្មភាពសុខភាពសាធារណៈត្រូវបានរៀបចំនៅជុំវិញ (i) មជ្ឈមណ្ឌលបង្អែកចំនួន ៣ ស្ថិតក្នុងផ្នែកវីរុសសាស្ត្រ (មជ្ឈមណ្ឌលបង្អែកជាតិសម្រាប់មេរោគគ្រុនផ្តាសាយ មន្ទីរពិសោធន៍បង្អែកថ្នាក់តំបន់របស់ WHO សម្រាប់មេរោគផ្តាសាយ H5) (ii) មជ្ឈមណ្ឌលធ្វើតេស្តមេរោគហ៊ីវ អនាមិក និងឥតគិតថ្លៃ និង មជ្ឈមណ្ឌលបង្ការជំងឺឆ្កែឆ្កួត នៅ ៣ ទីតាំង (ភ្នំពេញ បាត់ដំបង




និងកំពង់ចាម) ធានាអោយមានការបង្ការក្រោយសត្វខាំក្នុងតម្លៃជាក់លាក់សមស្រប។ ជាចុងក្រោយ វិទ្យាស្ថានមានវេទិកាបច្ចេកទេសចំនួន ៤ គឺ មន្ទីរពិសោធន៍ជីវសុវត្ថិភាពកម្រិតទី ៣ ទីតម្កល់វត្ថុវិភាគជីវសាស្ត្រ មន្ទីរពិសោធន៍វិភាគសេនេទិកមេរោគ និង មន្ទីរពិសោធន៍ញែករាប់កោសិកា ។

គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មានបុគ្គលិកចំនួន ២៩៣ នាក់។ ក្នុងនោះ មានអ្នកវិទ្យាសាស្ត្រកម្ពុជា ៩ រូប (ជានាយកស្រាវជ្រាវ ២ រូប ជាអ្នកស្រាវជ្រាវ ៧ រូប) ។ បុគ្គលិករួមមាន ១៤ សញ្ជាតិផ្សេងគ្នា ហើយ ៩០% ជាសញ្ជាតិខ្មែរ ។ វិទ្យាស្ថានផ្តល់សារៈសំខាន់យ៉ាងខ្លាំងចំពោះសមភាពបុរសស្ត្រី ៖ ៥៤% នៃបុគ្គលិកជាស្ត្រី។ ការអភិវឌ្ឍភាពជាអ្នកដឹកនាំផ្នែកវិទ្យាសាស្ត្រ និងការលើកកម្ពស់បុគ្គលិកបច្ចេកទេសជាតិគឺជាអាទិភាព។ ក្នុងចំណោមមុខងារគ្រប់គ្រងទាំង ១៦ ( នាយក ៣ នាក់ ប្រធានផ្នែកស្រាវជ្រាវ ឬផ្នែកសេវាកម្ម ៨ នាក់ ប្រធានផ្នែកសេវាទ្រទ្រង់ ៥ នាក់) មាន ១២ នាក់ជាបុរស (៧៥%) និង ៨ នាក់ជាជនជាតិខ្មែរ (៥០%) ។

វិទ្យាស្ថាននៅតែមានភាពស្វាហាប់ និងមានភាពទាក់ទាញខ្លាំង។ ដូចដែលលោកបណ្ឌិត *Jean-Louis Sarthou* បានកត់សម្គាល់រួចមកហើយក្នុងឆ្នាំ ២០០៧ ថា ៖ “មួយ ក្នុងចំណោមបណ្តាកត្តា ដែលកំរិតការអភិវឌ្ឍន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា គឺភាពតូចចង្អៀតរបស់ទីបន្ទប់បច្ចេកទេស និង របស់វិទ្យាស្ថានជាទូទៅ។ គ្រឹះដើមនៃអគារមិនអនុញ្ញាតឱ្យមានការសាងសង់មន្ទីរពិសោធន៍បន្ថែម មួយ ឬ ពីរជាន់ ទៅ



*ក្រុមប្រឹក្សាទំនាក់ទំនងដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងសុខាភិបាល (២០២២)*

លើទេ។ ដូច្នេះ នឹងចាំបាច់ត្រូវរៀបចំគ្រឹះឡើងវិញ ឬ សាងសង់អគារថ្មីមួយ នៅផ្លាខាងក្នុងវិទ្យាស្ថាន ពីខាងក្រោយមន្ទីរពេទ្យកាល់ម៉ែត» ។ ការវិភាគដូចគ្នានេះត្រូវបានធ្វើឡើងដោយក្រុមស្ថាបត្យកម្មមួយ ក្នុងឆ្នាំ ២០២២។ មានការពិចារណាមួយដើម្បីសិក្សារកដំណោះស្រាយណាមួយ ដែលនឹងអាចឈានទៅដល់ការផ្លាស់ប្តូររូបវន្តទ្រង់ទ្រាយធំមួយនៃវិទ្យាស្ថាន នាឆ្នាំ ២០៣០ ។

ដូចនេះហើយ បន្ទាប់ពីមានវត្តមានក្នុងប្រទេសកម្ពុជារយៈពេល ៧០ឆ្នាំមកនេះ វិទ្យា-ស្ថាន វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលជាសមាជិកនៃបណ្តាញវិទ្យាស្ថានប៉ាស្ទ័រ នៅតែបន្តបេសក-កម្មរបស់ខ្លួន ដោយប្រកាន់ខ្ជាប់ប្រពៃណីប៉ាស្ទ័រ ជាមួយនិងសមត្ថភាព និង ការតាំងចិត្ត ដើម្បីជាប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ និង តែងតែបម្រើដល់សុខភាពរបស់ប្រជាជនកម្ពុជា និងប្រជាជនក្នុងតំបន់ ។

**សាស្ត្រាចារ្យ André Spiegel**
នាយកវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

**សាស្ត្រាចារ្យ Jean-Luc Durosoir**
អគ្គប្រតិភូ បណ្តាញអន្តរជាតិនៃបណ្តាវិទ្យាស្ថានប៉ាស្ទ័រ (១៩៨៤-២០០១)



*បុគ្គលិកវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (២០២៣)*

# នាយក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា*

| | |
|---|---|
| Maurice HUARD | ១៩៥៣ - ១៩៥៥ |
| René TRIAUD | ១៩៥៥ - ១៩៦០ |
| Yves GOUEFFON | ១៩៦១ - ១៩៧៥ |
| François FLYE SAINTE MARIE | ១៩៩៤ - ១៩៩៩ |
| Yves BUISSON | ១៩៩៩ - ២០០១ |
| Jean-Louis SARTHOU | ២០០១ - ២០០៩ |
| Vincent DEUBEL | ២០០៩ - ២០១៤ |
| Didier FONTENILLE | ២០១៤ - ២០១៩ |
| Laurence BARIL | ២០១៩ - ២០២១ |
| André SPIEGEL | ២០២១ - |

# នាយករង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា*

| | |
|---|---|
| គ្រុយ ស៊ុនឡាយ | ១៩៩៤ - ២០១៧ |
| លី សុវត្ថិ | ២០១៧ - |

* ឈ្មោះថា វិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ រហូតដល់ ឆ្នាំ១៩៥៧

# ប្រភពព័ត៌មាន

*ឯកសារប្រវត្តិនេះភាគច្រើនត្រូវបានដកស្រង់ចេញពីឯកសារខាងក្រោម ៖*


*Anonyme.* Inauguration de l'Institut Pasteur du Cambodge. Campus. N°24. Mai 1995

*AUDIERE M.* Une visite de l'Institut Pasteur de Phnom-Penh. Cambodge, avril 1954, p. 36-40.

*DEDET Jean Pierre.* Institut Pasteur de Madagascar. In : Les Instituts Pasteur d'Outre-Mer. Cent vingt ans de microbiologie française dans le monde. France. L'Harmattan. 2000. 180-188.

*Collectif.* L'Institut Pasteur du Cambodge. 60 ans d'histoire au service de la santé. Fascicule édité à l'occasion des 60 ans de l'Institit Pasteur du Cambodge.

*DUROSOIR Jean-Luc.* Histoire de l'Institut Pasteur de Phnom Penh. 1994.

*MARNEFFE Hubert.* Le rôle de l'Institut Pasteur dans la prévention des maladies infectieuses au Viet-Nam, au Cambodge et au Laos. La Recherche Médicale Française. Novembre 1956. p 9-15.

*GOUEFFON Yves.* L'Institut Pasteur du Cambodge a 15 ans. Etudes Cambodgiennes. 1969, n°18, 20-27.

*TRIAU R.* Présentation de l'Institut Pasteur du Cambodge. 30 mai 1958. 8 pages.

*Conception & layout : Impact.com.kh*
*Technical Realisation : Anne-Céline Prigent*
*Photo Credit: Jean-François Perigois*

*Phnom Penh | May 2023*

70 ans years
1953-2023
Institut Pasteur
du Cambodge